# គណនីប្រតិបត្តិការ និងគណនីប្រាក់បញ្ញើ

លក្ខន្តិកៈ | មិថុនា ២០២២

J Trust Royal Bank

ឯកសារនេះរួមបញ្ចូលលក្ខខណ្ឌសម្រាប់ប្រភេទគណនីប្រតិបត្តិការ និងគណនីប្រាក់បញ្ញើដូចខាងក្រោមនេះ៖

## ផលិតផល

គណនី The ONE (បុគ្គល)
គណនីបង្កើនប្រាក់សន្សំ (បុគ្គល)
គណនីសន្សំ Goal (បុគ្គល)
គណនី Premier (បុគ្គល)
គណនី Premier Savings Plus (បុគ្គល)
គណនីមូលប្បទានប័ត្របុគ្គល (បុគ្គល)
គណនីមូលប្បទានប័ត្រពាណិជ្ជកម្ម
គណនីគ្រប់គ្រងសាច់ប្រាក់ (ពាណិជ្ជកម្ម)
គណនីប្រាក់បញ្ញើមានកាលកំណត់ (ពាណិជ្ជកម្ម និងបុគ្គល)
គណនីរូបិយប័ណ្ណបរទេស (ពាណិជ្ជកម្ម និងបុគ្គល)
កាតឥណពន្ធវីសា (បុគ្គល)

ឯកសារនេះត្រូវអានជាមួយកូនសៀវភៅនិយាយពីការគិតកម្រៃ និងថ្លៃសេវាកម្មរបស់ធនាគារ ដេ ត្រាស់ រ៉ូយ៉ាល់។ ឯកសារទាំងពីរនេះបង្កើតបានជាលក្ខខណ្ឌដែលត្រូវយកមកអនុវត្តជាមួយផលិតផលខាងលើ។

## តារាងមាតិកា ទំព័រ


1. សេចក្តីផ្តើម ........................................1
2. និយមន័យផ្សេងៗទាក់ទងនឹងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់........................................1
3. ការអនុវត្តចំពោះលក្ខខណ្ឌទាំងនេះ ........................................4
4. សិទ្ធិក្នុងការធ្វើប្រតិបត្តិការគណនី ........................................5
5. ថ្លៃសេវាកម្ម កម្រៃ និងការប្រាក់ ........................................5
   5.1. កាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ........................................5
6. របាយការណ៍គណនី និងឯកសារឆ្លើយឆ្លង ........................................7
7. គណនីរួម ........................................7
8. មូលប្បទានប័ត្រ និងមូលនិធិដែលបានផ្ទៀងផ្ទាត់រួច ........................................8
9. ការកែប្រែថ្លៃសេវាកម្ម អត្រាការប្រាក់ និងលក្ខខណ្ឌ ........................................9
10.ការទទួលខុសត្រូវរបស់លោកអ្នកចំពោះប្រតិបត្តិការដែលគ្មាន ការអនុញ្ញាត ...............10
11.ការរក្សាការសម្ងាត់ ........................................11
12.ការរំខានដល់សេវាកម្ម ........................................11
13.ការផ្តល់ឥណទាន ........................................11
14.ការប្រឆាំងការលាងលុយ ភេរវកម្មហិរញ្ញវត្ថុ និងការត្រួតពិនិត្យហិរញ្ញវត្ថុ ...................12
15.ការប្តូរឈ្មោះ និងអាស័យដ្ឋានដោយហត្ថលេខី ........................................13
16.សិទ្ធិរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ក្នុងការបញ្ចូលគណនីជាគណនីតែមួយ .............13
17.រូបិយប័ណ្ណ ........................................13
18.ចំនួនទឹកប្រាក់ដែលជំពាក់ ........................................13
19.ការបិទគណនីធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នក ........................................14
   19.1. ការបិទគណនីនៅស្ងៀម ឬគ្មានសកម្មភាព ........................................14
   19.2. ការបិទគណនីនៅស្ងៀម ឬគ្មានសកម្មភាពក្នុងរយៈពេលដប់ (១០)ឆ្នាំជាប់គ្នា ....15
20.លក្ខខណ្ឌច្បាស់លាស់សំរាប់ប្រាក់បញ្ញើមានកាលកំណត់........................................15
21.សេវាកម្មភាគីទី3 ........................................15
22.សំណង ........................................15
23.សេចក្តីជូនដំណឹង និងការព្រមព្រៀង ........................................15
24.លក្ខខណ្ឌនៃការប្រើប្រាស់សេវាកម្មធនាគារអេឡិចត្រូនិក ........................................16
   24.1. កម្រិតនៃកាតឥណពន្ធ ........................................16
   24.2. សុពលភាព និងកាលបរិច្ឆេទផុតកំណត់របស់កាតឥណពន្ធ ........................................17
   24.3. ការលុបចោល/ការបញ្ឈប់សេវាកម្មកាតឥណពន្ធ ឬសេវាកម្ម អេឡិចត្រូនិក.......17
   24.4. ការបញ្ឈប់ដំណើរការរបស់សេវាកម្មអេឡិចត្រូនិក ........................................18
   24.5. ការផ្លាស់ប្តូរប្រតិបត្តិការតាមរយៈម៉ាស៊ីនអេឡិចត្រូនិក ........................................19
   24.6. ការទទួលខុសត្រូវរបស់លោកអ្នកចំពោះកាតឥណពន្ធ និងលេខកូដសម្ងាត់.......19
   24.7. ការចេញរបាយការណ៍ប្រតិបត្តិការ ........................................19
   24.8. ចំនួនទឹកប្រាក់កំណត់របស់ប្រតិបត្តិការ ........................................19
   24.9. កាតឥណពន្ធរង ........................................22
   24.10. ប្រតិបត្តិការបង្វិលប្រាក់សងវិញ ........................................22
   24.11. ការដកចេញ និងការលើកលែង ........................................22
25. ភាពមិនត្រូវគ្នា ........................................25
26. ការផ្ទេរសិទ្ធិ ........................................25
27. ច្បាប់គ្រប់គ្រង ........................................25
28. ពន្ធ ........................................25
29. ការប្រមូលព័ត៌មាន ........................................25
30. ទំនាក់ទំនងតាមទូរស័ព្ទ ........................................26

## 1. សេចក្តីផ្តើម

លក្ខខណ្ឌទាំងនេះត្រូវអនុវត្តចំពោះគណនីធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលបានបញ្ជាក់ ជូននៅទំព័រក្របមុខនៃកូនសៀវភៅនេះ (លក្ខន្តិកៈ)។ ជាការសំខាន់លោកអ្នកត្រូវអានលក្ខខណ្ឌទាំងនេះមុនពេលសំរេចចិត្តបើក និង ធ្វើប្រតិបត្តិការធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ណាមួយដែលបានបញ្ជាក់ខាងលើ។ ប្រសិនបើលោកអ្នកមិនយល់ ឬមិនច្បាស់អំពីចំនុចណាមួយនៃលក្ខខណ្ឌទាំងនេះ សូមសាកសួរធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដើម្បីទទួលបានការពន្យល់ទាក់ទងនឹងចម្ងល់លោកអ្នក។

លក្ខខណ្ឌទាំងនេះត្រូវអាន និងអនុវត្តជាមួយលក្ខខណ្ឌដែលមាននៅក្នុងកូនសៀវភៅ "ការកំណត់សេវាកម្មរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់"។

បន្ថែមលើលក្ខខណ្ឌដែលមានបញ្ជាក់ទាំងនេះ លក្ខខណ្ឌផ្សេងៗទៀតរួមទាំងលក្ខខណ្ឌដែលកំណត់ដោយច្បាប់ក៏ត្រូវបានអនុវត្តផងដែរ។

## 2. និយមន័យផ្សេងៗទាក់ទងនឹងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

នៅក្នុងលក្ខខណ្ឌទាំងនេះ និយមន័យខាងក្រោមនេះ ត្រូវបានអនុវត្តជាទូទៅលើកលែងតែមានការបញ្ជាក់ណាមួយ៖

"**គណនី**" មានន័យថា គណនីដែលបានយកមកអនុវត្តតាមលក្ខខណ្ឌទាំងនេះ គណនីរួមមានដូចដែលបានបញ្ជាក់នៅលើគម្របកូនសៀវភៅនេះ។

**"របាយការណ៍គណនី"** មានន័យថា របាយការណ៍ដែលចេញដោយធនាគារជេ ត្រាស់ រ៉ូយ៉ាល់ លើចំនួនទឹកប្រាក់ដែលត្រូវបានយកថ្លៃសេវាកម្ម ឬត្រូវបានដកចេញពីគណនី និង/ឬសងទៅកាន់គណនី ហើយរបាយការណ៍គណនីនេះអាចធ្វើឡើងក្នុងទម្រង់ជាក្រដាស ឬអេឡិចត្រូនិក។

**"ម្ចាស់គណនី"** មានន័យថា បុគ្គលម្នាក់ ឬច្រើននាក់ ដែលប្រើឈ្មោះរបស់ខ្លួននៅពេលបើកគណនី ហើយបុគ្គលនោះគឺទទួលខុសត្រូវចំពោះគណនីតាមរយៈហត្ថលេខាប្រគល់សិទ្ធ។ ប្រសិនបើគណនីមានម្ចាស់ច្រើន នោះពាក្យម្ចាស់គណនី សំដៅលើម្ចាស់គណនីទាំងអស់ និងបុគ្គលរៀងៗខ្លួន។

**"សំណុំបែបបទ និងកិច្ចព្រមព្រៀង (តទៅនេះត្រូវហៅថា សំណុំបែបបទ)"** មានន័យថា សំណុំបែបបទក្នុងទម្រង់មួយដែលតម្រូវ ហើយត្រូវបានបំពេញ និងប្រគល់ជូនដើម្បីអនុញ្ញាតឱ្យអ្នកផ្តល់កាតសម្រេចថា អ្នកបំពេញសំណុំបែបបទអាចក្លាយទៅជាអ្នកប្រើប្រាស់កាត ហើយដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា។

**"ATM"** មានន័យថា ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិដែលតំឡើងដោយ ឬជាកម្មសិទ្ធិរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬធនាគារជាសមាជិកនៃបណ្តាញ Visa/PLUS ឬប្រព័ន្ធនៃការផ្ទេរមូលនិធិតាមបែបអេឡិចត្រូនិកក្រៅពី Visa/PLUS ឬឧបករណ៍នានា ឬ សម្រាប់ប្រតិបត្តិការទូទាត់សងតាមម៉ាស៊ីន ឬការផ្ទេរមូលនិធិតាមមធ្យោបាយអេឡិចត្រូនិកដែលជូនដំណឹងដោយយើងខ្ញុំទៅកាន់លោកអ្នក នៅពេលណាមួយនាពេលអនាគត។

**"កម្រិតនៃការប្រើប្រាស់ ATM"** មានន័យថា កម្រិតអតិបរមាដែលអនុញ្ញាតក្នុងការដកសាច់ប្រាក់ និង/ឬប្រតិបត្តិការដទៃដែលត្រូវប្រើប្រាស់តាមរយៈម៉ាស៊ីន ATM ក្នុងថ្ងៃណាមួយ ហើយកម្រិតនៃការប្រើប្រាស់ ATM នេះ ត្រូវបានកំណត់ដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។

**"អ្នកទទួលបានសិទ្ធប្រើប្រាស់"** នៅក្នុងគោលបំណងនៃលក្ខខណ្ឌទាំងនេះ មានន័យថា បុគ្គលម្នាក់ ឬច្រើននាក់ដែលបានកំណត់ ឬត្រូវបានផ្តល់សិទ្ធិដោយម្ចាស់គណនីដើម្បីធ្វើប្រតិបត្តិការគណនីរបស់ខ្លួនដោយយោងតាមលក្ខខណ្ឌទី 4។

**"សមតុល្យដែលមាន"** មានន័យថា ពាក់ព័ន្ធនឹងគណនីណាមួយចំនួនសរុបនៃៈ

(ក) សមតុល្យក្នុងគណនីរបស់លោកអ្នកដែលមាន និងជាមូលនិធិដែលអាចផ្ទេរបានដោយសេរី និង

(ខ) ខណៈដែលយើងខ្ញុំផ្តល់ជូនឥណទានវិបារូបន៍ ឬកម្រិតឥណទានដែលជូនដំណឹងដោយយើងខ្ញុំទៅកាន់លោកអ្នក ដកចំនួនប្រាក់សរុបដែលលោកអ្នកជំពាក់យើងខ្ញុំទាក់ទងនឹងឥណទានវិបារូបន៍ ឬកម្រិតឥណទាននោះ។

**"ការផ្ទេរសមតុល្យ"** មានន័យថា នៅពេលដែលមូលនិធិត្រូវបានដាក់ចូលក្នុងគណនីកាតឥណពន្ធដទៃទៀតដែលកាន់កាប់ដោយម្ចាស់គណនី ប៉ុន្តែមិនមែនជាគណនីរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ។

**"ផលប្រយោជន៍"** មានន័យថា ផលប្រយោជន៍ផ្តល់ដោយធនាគារ និងផលប្រយោជន៍របស់ពាណិជ្ជករជារួម។

**"ថ្ងៃធ្វើការ"** មានន័យថា ជាថ្ងៃដែលមិនរាប់បញ្ចូលថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកជាសាធារណៈក្នុងប្រទេសកម្ពុជា។

**"អ្នកប្រើប្រាស់កាត"** រាប់បញ្ចូលអ្នកប្រើប្រាស់កាត និង/ឬអ្នកប្រើប្រាស់កាតរងស្របតាមលក្ខខណ្ឌដែលមានចែង។

**"អ្នកផ្តល់កាត"** សំដៅលើធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងក្រុមហ៊ុន ឬ ភ្នាក់ងារដែលបានកំណត់ និងអ្នកទទួលសិទ្ធិបន្ត។

**"ប្រតិបត្តិការមិនបង្ហាញកាត"** មានន័យថា ប្រតិបត្តិការដែលត្រូវបានធ្វើឡើងក្នុងបរិបទពាណិជ្ជកម្មដោយម្ចាស់គណនី និងកាតឥណពន្ធមិនត្រូវបានបង្ហាញនាពេលប្រើប្រាស់។ ជាធម្មតាប្រតិបត្តិការមិនបង្ហាញកាតរួមបញ្ចូល តែមិនកំណត់ត្រឹមប្រតិបត្តិការដែលធ្វើឡើងតាមអ៊ីនធឺណេត អ៊ីមែល ទូរស័ព្ទ ឬការបញ្ជាតាមទូរសារ ឬការកក់ទុក ឬការកើតឡើងដដែលៗនៃការទូទាត់សងប្រាក់។

**"កម្មវិធីកាត"** មានន័យថាៈ

(ក) កាតឥណពន្ធដែលលោកអ្នកបានស្នើសុំ ហើយយើងខ្ញុំបានផ្តល់ជូនលោកអ្នកស្របតាមកិច្ចព្រមព្រៀងនេះ។

(ខ) ការផ្តល់រង្វាន់ អតិថិជនទៀងទាត់ (Loyalty) អភ័យឯកសិទ្ធិ ឬកម្មវិធីផ្សព្វផ្សាយម៉ាករួមគ្នា (Co-branding Programmes) និងសេវាកម្មដែលពាក់ព័ន្ធនឹងផលិតផល (ជារួមហៅថា "ផលប្រយោជន៍ផ្តល់ដោយធនាគារ") ដែលជាឆន្ទានុសិទ្ធិរបស់យើងខ្ញុំក្នុងការផ្តល់ជូនលោកអ្នកដោយភ្ជាប់ជាមួយនឹងសេវាកម្មកាតឥណពន្ធ។ និង

(គ) ការបញ្ចុះតម្លៃ អភ័យឯកសិទ្ធិ ការលើកទឹកចិត្ត ការផ្តល់ជូនសេវាកម្ម និង/ឬផលិតផល (ជារួមហៅថា "ផលប្រយោជន៍របស់ពាណិជ្ជករ") ដែលត្រូវបានផ្តល់ជូនលោកអ្នកដោយភ្ជាប់ជាមួយនឹងសេវាកម្មកាតឥណពន្ធ ឬដែលកើតឡើងដោយលោកអ្នកដែលជាអ្នកប្រើប្រាស់កាតឥណពន្ធ និងនាពេលដែលផលប្រយោជន៍របស់ពាណិជ្ជករនេះត្រូវបានផ្តល់ជូនដោយដៃគូផ្សព្វផ្សាយ ម៉ាករួមគ្នា និងពាណិជ្ជករ/តតិយជន (ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មនៅពេលមួយនាពេលអនាគត)។ លោកអ្នកទទួលស្គាល់ និងយល់ព្រមថា ផលប្រយោជន៍ផ្តល់ដោយធនាគារ និង/ឬ ផលប្រយោជន៍របស់ពាណិជ្ជករ អាចត្រូវបានកែប្រែ បញ្ចប់ ផ្លាស់ប្តូរ ដោយយើងខ្ញុំនាពេលណាមួយតាមឆន្ទានុសិទ្ធិតែមួយគត់របស់យើងខ្ញុំ ដោយពុំមានបំណុលណាមួយកើតមានឡើងទៅលើលោកអ្នក។

**"ប្រតិបត្តិការដោយប្រើប្រាស់កាត"** មានន័យថា ប្រភេទនៃប្រតិបត្តិការណាមួយដែល

មានសុពលភាពតាមរយៈការប្រើប្រាស់កាតឥណពន្ធ គណនី ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួន (និងរាប់បញ្ចូលនូវរាល់ប្រតិបត្តិការដកសាច់ប្រាក់)។

**"ប្រតិបត្តិការដកសាច់ប្រាក់"** មានន័យថា ការដកមូលនិធិក្នុងទម្រង់ជារូបិយប័ណ្ណណាមួយពីគណនីណាមួយចេញពីសមតុល្យ (ដោយសមតុល្យនោះមិន ឬនឹងមិនមានលទ្ធផលសមតុល្យដកលើស ហើយថាតើស្ថិតក្នុងទម្រង់ជាសាច់ប្រាក់ឬទេ) ដោយសារ ឬតាមរយៈ ឬពាក់ព័ន្ធជាមួយនឹងកាតឥណពន្ធ។

**"សេវាកម្មអេឡិចត្រូនិក"** មានន័យថា រាល់សេវាកម្ម ឬផលិតផលដែលយើងខ្ញុំបានបង្កើតឡើងសម្រាប់លោកអ្នកពីពេលមួយទៅពេលមួយ ហើយដែលត្រូវបានផ្តល់ជូនតាមរយៈមធ្យោបាយអេឡិចត្រូនិក ដោយរាប់បញ្ចូលកាត ការគណនា អេឡិចត្រូនិក ឬឧបករណ៍ទាក់ទង ឬវិធីធ្វើប្រតិបត្តិការគណនីក្នុង ឬក្រៅប្រទេសកម្ពុជា និងដែលតម្រូវដោយកាលៈទេសៈដូចជាលេខកូដសម្ងាត់ផ្ទាល់ខ្លួន និង/ឬកាតឥណពន្ធដែលត្រូវបានប្រើប្រាស់ដើម្បីប្រើសេវាកម្មអេឡិចត្រូនិក។

**"គណនីរួមគ្នា"** មានន័យថា គណនីដែលមានម្ចាស់រួមគ្នាច្រើនជាងម្នាក់។

**"ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់"** មានន័យថា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងក្រុមហ៊ុន ឬភ្នាក់ងារដែលបានកំណត់ និងទទួលសិទ្ធបន្ត។

**"គណនីប្រាក់បញ្ញើមានកាលកំណត់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់"** មានន័យថាគណនីប្រាក់បញ្ញើមានកាលកំណត់ (សម្រាប់អតិថិជនបុគ្គល និងអាជីវកម្ម)។

**"កាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់/កាតឥណពន្ធ"** មានន័យថា កាតឥណពន្ធស្តង់ដារ កាត ATM ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ (J Trust Royal ATM access card) កាតឥណពន្ធ Visa ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ កាតឥណពន្ធ Visa Premier ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និង កាតឥណពន្ធដែលចារឈ្មោះថា Visa និង/ឬសេវាសញ្ញា Visa ដែលចេញដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលអនុញ្ញាតឱ្យអ្នកអាចធ្វើប្រតិបត្តិការតាមម៉ាស៊ីន ATM ឬ/និងប្រតិបត្តិការដោយប្រើប្រាស់កាត និងរាល់ការជំនួសការផ្លាស់ប្តូរ ឬការធ្វើថ្មី។

**"ច្បាប់"** មានន័យថា ច្បាប់បទបញ្ជា លិខិតប្រកាសបទបញ្ញត្តិដោយច្បាប់ក្នុងការកំណត់ក្រមអនុវត្ត ក្រមសីលធម៌ ឬតម្រូវការកំណត់ក្នុងគោលបំណងពង្រឹងនីតិរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។

**"ពាណិជ្ជករ"** មានន័យថា រាល់បុគ្គល ក្រុមហ៊ុន ឬសាជីវកម្ម/អង្គការ ដែលចុះកិច្ចព្រមព្រៀងជាមួយធនាគារ ឬសមាជិកណាមួយ ឬអ្នកទទួលអាជ្ញាប័ណ្ណពី Visa ឬអ្នកផ្តល់សេវាកម្មអេឡិចត្រូនិកណាមួយពាក់ព័ន្ធនឹងការប្រើប្រាស់ និង/ឬការទទួលយកកាតឥណពន្ធ ក្នុងការទូទាត់សងប្រាក់ទៅកាន់បុគ្គលទាំងនោះ ជាទំនិញ សេវាកម្ម ឬកម្រៃដែលផ្តល់ជូន។

**"សមតុល្យដែលលើស"** មានន័យថា សមតុល្យអវិជ្ជមានក្នុងគណនី ដោយជាប់ពាក់ព័ន្ធជាមួយនឹងគណនីណាមួយ។

**"ទិន្នន័យផ្ទាល់ខ្លួន"** មានន័យថា ទិន្នន័យ មិនថាពិតប្រាកដ ឬមិនពិតប្រាកដអំពីបុគ្គលដែលអាចសម្គាល់បានដោយៈ

(ក) តាមរយៈទិន្នន័យនោះ ឬ

(ខ) តាមរយៈទិន្នន័យនោះ និងព័ត៌មានដទៃដែលអង្គភាពមាន ឬដែលអាចនឹងមាន។

**"លេខកូដសម្ងាត់ផ្ទាល់ខ្លួន"** មានន័យថា រាល់លេខសម្គាល់អត្តសញ្ញាណផ្ទាល់ខ្លួនដែលផ្តល់ដោយយើងខ្ញុំដើម្បីអនុញ្ញាតអោយលោកអ្នកប្រើប្រាស់កាតឥណពន្ធតាម

រយៈម៉ាស៊ីន ATM ឧបករណ៍ធ្វើប្រតិបត្តិការលក់សម្រាប់ការទទួលបានប្រាក់មកវិញ (Cash Back) និង/ឬសិទ្ធិចូលទៅកាន់សេវាអេឡិចត្រូនិក។

**"ម្ចាស់គណនីចម្បង"** មានន័យថា បុគ្គលដែលមានឈ្មោះជាម្ចាស់គណនីនៅពេលបើកដំបូង។

**"ដំណើរការ"** ដោយជាប់ពាក់ព័ន្ធនឹងទិន្នន័យផ្ទាល់ខ្លួន មានន័យថា ការអនុវត្តប្រតិបត្តិការណាមួយ ឬបណ្តុំនៃប្រតិបត្តិការដែលពាក់ព័ន្ធនឹងទិន្នន័យផ្ទាល់ខ្លួន និងរាប់បញ្ចូលទាំងប្រតិបត្តិការដូចតទៅ៖

(ក) ការកត់ត្រា

(ខ) ការកាន់កាប់

(គ) ការរៀបចំ ការទទួលយក ឬការផ្លាស់ប្តូរ

(ឃ) ការទាញយកមកវិញ

(ង) ការរួមបញ្ចូល

(ច) ការបញ្ជូន

(ឆ) ការលុប ឬការបំផ្លាញ។

**"ប្រតិបត្តិការលក់"** មានន័យថា ការប្រើប្រាស់របស់អ្នកប្រើប្រាស់កាតឥណពន្ធដើម្បីទូទាត់ទំនិញ និង/ឬសេវាកម្ម។

**"កម្រិតចំណាយ"** មានន័យថា កម្រិតអតិបរមាប្រចាំថ្ងៃដែលកំណត់ដោយយើងខ្ញុំពាក់ព័ន្ធនឹងប្រតិបត្តិការដោយប្រើប្រាស់កាតឥណពន្ធរបស់លោកអ្នក។

**"ម្ចាស់គណនីរង"** មានន័យថា បុគ្គលដែលត្រូវបានអនុញ្ញាតឱ្យ កាន់គណនីរួមជាមួយម្ចាស់គណនីចម្បង។

**"ការបញ្ចប់"** សំដៅលើ ការព្យួរ ការបញ្ចប់ ឬការលុបចោលកាតឥណពន្ធរាប់បញ្ចូលទាំងអភ័យឯកសិទ្ធិទាំងអស់នៃកាតឥណពន្ធ និងលក្ខណៈសម្បត្តិរបស់វា។

**"USD"** មានន័យថា រូបិយបណ្ណផ្លូវការ ដុល្លារសហរដ្ឋអាមេរិក។

**"លោកអ្នក"** មានន័យថា លើកលែងតែមានការបញ្ជាក់ដោយឡែកជាម្ចាស់គណនី និងអ្នកទទួលបានសិទ្ធប្រើប្រាស់ ("របស់លោកអ្នក មានអត្ថន័យទាក់ទងនឹងពាក្យនេះ")។

## 3. ការអនុវត្តចំពោះលក្ខខណ្ឌទាំងនេះ

លក្ខខណ្ឌទាំងនេះនឹងត្រូវបានយកមកអនុវត្តភ្លាមៗ ចំពោះគណនីនីមួយៗ ដែលលោកអ្នកបានបើកជាមួយនឹងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។ លក្ខខណ្ឌទាំងនេះត្រូវយកមកអនុវត្តចំពោះលោកអ្នក និងអ្នកស្នងមរតកស្របច្បាប់របស់លោកអ្នក និង/ឬអ្នកទទួលមរតកដែលមានការទទួលស្គាល់ស្របច្បាប់។

លក្ខខណ្ឌទាំងនេះត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌផ្សេងៗទៀតដែលអាចយកមកអនុវត្តសម្រាប់ប្រតិបត្តិការជាក់លាក់ ឬ សេវាកម្មទាក់ទងនឹងគណនីរបស់លោកអ្នក (លក្ខខណ្ឌជាក់លាក់)។ ប្រសិនបើមិនមានចែងផ្ទុយពីលក្ខខណ្ឌជាក់លាក់ទេ បើមានភាពមិនចុះសម្រុងគ្នារវាងលក្ខខណ្ឌទាំងនេះ និងលក្ខខណ្ឌជាក់លាក់ លក្ខខណ្ឌទាំងនេះនឹងត្រូវយកមកអនុវត្ត។

លក្ខខណ្ឌទាំងនេះអាច នឹងត្រូវបានកែប្រែម្តងម្កាលតាមរយៈការព្រមព្រៀងជាមួយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬ ដោយការជូនដំណឹងដែលធ្វើឡើងដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ក្រោមលក្ខខណ្ឌទី9។

## 4. សិទ្ធិក្នុងការធ្វើប្រតិបត្តិការគណនី

នៅពេលដែលលោកអ្នកបើកគណនី លោកអ្នកត្រូវជ្រើសរើសបុគ្គលណាមួយ ឬច្រើនជាងម្នាក់ដែលមានសិទ្ធិធ្វើប្រតិបត្តិការគណនី។ ប្រសិនបើលោកអ្នកមានបំណងចង់ ប្តូរមនុស្សដែលមានសិទ្ធិក្នុងការធ្វើប្រតិបត្តិការគណនី លោកអ្នកត្រូវជូនព័ត៌មានមកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ជាលាយលក្ខណ៍អក្សរ។ លើកលែងតែក្នុងករណីដែលមានការព្រមព្រៀងគ្នាច្បាស់លាស់ជាមួយ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បើពុំដូច្នោះទេ ធនាគារ ជេ ត្រាស់រ៉ូយ៉ាល់ អាចអនុវត្តបានគ្រប់ពេលវេលាទាំងអស់ដោយផ្អែកលើមូលដ្ឋានអ្នកមានសិទ្ធិប្រតិបត្តិការម្នាក់ ឬច្រើននាក់ដែលត្រូវបានប្រគល់សិទ្ធិដោយលោកអ្នក ដែលមានសិទ្ធិពេញលេញក្នុងការធ្វើកិច្ចការ ឬដោះស្រាយបញ្ហា និងប្រតិបត្តិការគ្រប់បែបយ៉ាងទាក់ទងទៅនឹងគណនី (រួមទាំងការដកប្រាក់ផងដែរ)។

លោកអ្នកត្រូវទទួលខុសត្រូវលើរាល់កិច្ចការ និងប្រតិបត្តិការទាំងអស់នៃគណនី។ ប្រសិនលោកអ្នកជាម្ចាស់គណនីរួមជាមួយនឹងមនុស្សម្នាក់ទៀត ឬមនុស្សច្រើននាក់ផ្សេងទៀត ការទទួលខុសត្រូវនឹងធ្វើឡើងរួមគ្នាលើរាល់កិច្ចការ និងប្រតិបត្តិការទាំងអស់ដែលទាក់ទងនឹងគណនី។

## 5. ថ្លៃសេវាកម្ម កម្រៃ និងការប្រាក់

រាល់គណនីទាំងអស់ គឺគណនីដែលត្រូវបានគិតថ្លៃសេវាកម្ម និងកម្រៃជាក់លាក់ដែលបានកំណត់ដោយមានការបញ្ជាក់ច្បាស់លាស់ក្នុងកូនសៀវភៅ “កម្រៃ និងថ្លៃសេវាកម្មរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់” ដែលមានការកែប្រែពីពេលមួយទៅពេលមួយ។ លោកអ្នកយល់ព្រមធ្វើការបង់ថ្លៃសេវាកម្ម និងកម្រៃផ្សេងៗ ហើយលោកអ្នកក៏បានយល់ព្រមឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដកដោយផ្ទាល់ចេញពីគណនីរបស់លោកអ្នក។

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងបង់ការប្រាក់ផ្អែកទៅលើចំនួនទឹកប្រាក់ ដែលមានក្នុងគណនីរបស់លោកអ្នកក្នុងអត្រាមួយ ដែលបានជូនដំណឹងទៅលោកអ្នក (ស្របតាមលក្ខខណ្ឌ ទី 9) ហើយស្របតាមបែបបទស្តង់ដារផងដែរ។

### 5.1. កាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

(ក) លោកអ្នកយល់ព្រមបង់រាល់ការប្រាក់ ថ្លៃសេវាកម្ម និងកម្រៃតាមអត្រាដែលបានកំណត់ និងចំនួន ហើយផ្អែកលើមូលដ្ឋាននេះ យើងខ្ញុំអាចកំណត់តាមឆន្ទានុសិទ្ធិសមស្របរបស់ខ្លួនពីពេលមួយទៅពេលមួយដែលពាក់ព័ន្ធនឹងការផ្តល់ និង/ឬ ការប្រើប្រាស់កាតឥណពន្ធរបស់លោកអ្នក។ រាល់កម្រៃដែលបានបញ្ជាក់ខាងលើមិនអាចត្រូវបានដកយកវិញទេ។ យើងខ្ញុំអាចដកចេញពីគណនីរបស់លោកអ្នកនូវចំនួនទឹកប្រាក់នៃរាល់កម្រៃ ថ្លៃសេវាកម្ម ពន្ធ និងរាល់ទឹកប្រាក់ដែលលោកអ្នកជំពាក់ ពាក់ព័ន្ធនឹងលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។

(ខ) យើងខ្ញុំអាចកែប្រែអត្រា ឬ ចំនួនទឹកប្រាក់នៃថ្លៃសេវាកម្ម ឬ កម្រៃដែលជំពាក់ ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដោយឆន្ទានុសិទ្ធិរបស់យើងខ្ញុំ។ ការកែប្រែ និងមានសុពលភាពចាប់ពីថ្ងៃដែលបានកំណត់ក្នុងលិខិតជូនដំណឹង។ ប្រសិនបើលោកអ្នកបន្តរក្សា ឬប្រើប្រាស់កាតឥណពន្ធក្រោយពីថ្ងៃដែលបានបញ្ជាក់ខាងលើលោកអ្នកនឹងត្រូវចាត់ទុកថាយល់ព្រមទទួលការកែប្រែនោះ។

(គ) លោកអ្នកត្រូវទទួលខុសត្រូវចំពោះរាល់ពន្ធលើទំនិញ និងសេវាកម្ម និងរាល់ពន្ធដែលកំណត់លើ ឬ ជំពាក់លើរាល់ទឹកប្រាក់ទាំងឡាយណាដែលតម្រូវឱ្យទូទាត់សងស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ យើងខ្ញុំនឹងដកចេញនូវទឹកប្រាក់នៃពន្ធនោះទៅកាន់គណនីរបស់លោកអ្នក។

(ឃ) យើងខ្ញុំត្រូវបានផ្តល់សិទ្ធិក្នុងការដកចេញពីគណនីរបស់លោកអ្នក ឬ គណនីដទៃផ្សេងទៀតរបស់លោកអ្នកដែលរក្សាជាមួយយើងខ្ញុំដែលពាក់ព័ន្ធនឹងទឹកប្រាក់ដែលលោកអ្នកជំពាក់យើងខ្ញុំ (ទោះជាកើតឡើងតាមរយៈប្រតិបត្តិការដោយប្រើប្រាស់កាត កម្រៃ ថ្លៃសេវាកម្ម ឬផ្សេងពីនេះ) ទោះបីជាគណនីរបស់លោកអ្នកអាចនឹងត្រូវបណ្តាលឱ្យមានសមតុល្យអវិជ្ជមានក៏ដោយ។

(ង) ប្រសិនបើរាល់ការទូទាត់ទាំងឡាយណាដែលធ្វើឡើងដោយយើងខ្ញុំដែលកើតឡើងពីការប្រើប្រាស់របស់លោកអ្នក ឬការប៉ុនប៉ងប្រើប្រាស់នៃសេវាកម្មអេឡិចត្រូនិកៈ

- ហើយគណនីត្រូវបានដកចេញ ប៉ុន្តែឥណពន្ធនោះត្រូវបានប្រែទៅជាមានកំហុស ឬ គណនីមិនត្រូវបានដកចេញ។ ឬ
- បន្ទាប់ពីការបញ្ជាសងបានកើតមានឡើង ប៉ុន្តែមុនការបញ្ជាសងនោះត្រូវបានទទួលស្គាល់។

ដូចនេះ យើងខ្ញុំមានសិទ្ធិកែតម្រូវគណនីតាមរយៈៈ

- ដកចេញពីគណនីជាមួយនឹងទឹកប្រាក់ដែលត្រូវបានបង់ដោយយើងខ្ញុំ ឬ
- ដោយមិនទទួលស្គាល់ ឬ ការប្រគល់ត្រលប់នូវមូលប្បទានបត្រ ឬ ឧបករណ៍ដទៃទៀត និងកែប្រែការបញ្ជាសង ប្រសិនបើពុំមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីដែលអាចកើតមានឡើង។

(ច) 1. ប្រតិបត្តិការដោយការប្រើប្រាស់កាត ដែលត្រូវបានធ្វើឡើងក្នុងទម្រង់រូបិយប័ណ្ណផ្សេងក្រៅពីរូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិក (“ប្រតិបត្តិការឆ្លងព្រំដែន”) នឹងត្រូវបានដកប្រាក់ចេញពីគណនីរបស់លោកអ្នក បន្ទាប់ពីការប្តូរទៅជារូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិកតាមអត្រាប្តូរប្រាក់ ដែលកំណត់ដោយ **Visa**។ អត្រាប្តូរប្រាក់នេះត្រូវបានកំណត់យកនាថ្ងៃដែលប្រតិបត្តិការប្រើប្រាស់កាតត្រូវបានបញ្ចូលទៅក្នុងគណនីកាតឥណពន្ធ ហើយអត្រាប្តូរប្រាក់នេះអាចខុសពីអត្រាប្តូរប្រាក់នាថ្ងៃប្រតិបត្តិការដោយប្រើប្រាស់កាតនោះត្រូវបានធ្វើឡើង។ ប្រតិបត្តិការឆ្លងព្រំដែន ត្រូវរាប់បញ្ចូលទាំងប្រតិបត្តិការដោយប្រើប្រាស់កាត (ក្នុងទម្រង់រូបិយប័ណ្ណណាក៏ដោយ) ដែលត្រូវធ្វើឡើងជាមួយនឹងពាណិជ្ជករដែលប្រតិបត្តិការក្រៅប្រទេសកម្ពុជា។ គ្រប់ប្រតិបត្តិការឆ្លងព្រំដែនត្រូវផ្អែកលើៈ

- ថ្លៃសេវាកម្មដែលកំណត់ដោយ Visa
- រាល់កម្រៃដែលត្រូវបានរកឃើញដោយយើងខ្ញុំលើប្រតិបត្តិការដោយប្រើប្រាស់កាតក្នុងរូបិយប័ណ្ណផ្សេងក្រៅពីរូបិយប័ណ្ណដុល្លារអាមេរិក។ ខណៈដែលប្រតិបត្តិការដោយប្រើប្រាស់កាតពាក់ព័ន្ធនឹងគណនីដែលមិនមែនរូបិយប័ណ្ណដុល្លារអាមេរិក យើងខ្ញុំមានសិទ្ធិអនុវត្តតាមអត្រាប្តូរប្រាក់ដែលត្រូវអនុវត្ត។

2. ទោះបីជាមានការចែងដូចខាងលើ ប្រសិនបើលោកអ្នកសម្រេចជ្រើសរើសការប្តូរប្រតិបត្តិការសាច់ប្រាក់របស់លោកអ្នកពីប្រតិបត្តិការតាមម៉ាស៊ីន ATM ឬ ប្រតិបត្តិការដោយប្រើប្រាស់កាតដែលបើកជារូបិយប័ណ្ណបរទេសទៅកាន់រូបិយប័ណ្ណដុល្លារអាមេរិកតាមរយៈ សេវាកម្ម Dynamic Currency Conversion ឬ រូបិយប័ណ្ណដែលអ្នកប្រើប្រាស់កាតពេញចិត្តនឹងទទួលយកដែលផ្តល់ដោយម៉ាស៊ីន ATM ក្រៅស្រុក និងពាណិជ្ជករ នោះលោក

អ្នកទទួលស្គាល់ថាដំណើរការនៃការប្តូរប្រាក់ និងអត្រាប្តូរប្រាក់ដែលត្រូវយកមកអនុវត្ត គឺត្រូវកំណត់ដោយប្រតិបត្តិការម៉ាស៊ីន ATM ដែលពាក់ព័ន្ធ ពាណិជ្ជករ ឬ អ្នកផ្គត់ផ្គង់សេវាកម្ម Dynamic Currency Conversion ដែលអាចកើតមានឡើង។ បន្ថែមពីនេះ ការប្តូរនេះត្រូវស្របតាម៖

- ថ្លៃសេវាកម្មដែលកំណត់ដោយ Visa និង
- កម្រៃទាំងឡាយណាដែលរកឃើញដោយយើងខ្ញុំលើប្រតិបត្តិការដោយប្រើប្រាស់កាត។

3. យើងខ្ញុំនឹងដាក់ចូលក្នុងគណនីណាមួយរបស់លោកអ្នកនូវទឹកប្រាក់ដែលអាចដកយកវិញទាក់ទិននឹងប្រតិបត្តិការដោយប្រើប្រាស់កាតណាមួយ ឬ ការទូទាត់សងប្រាក់ ឬ ឥណទានណាមួយដែលលោកអ្នកជំពាក់ នាខណៈពេលដែលយើងខ្ញុំអាចកំណត់បន្ទាប់ពីទទួលបានចំនួនទឹកប្រាក់សង ការទូទាត់សង ឬឥណទានទាំងនោះក្នុងប្រទេសកម្ពុជា។ ប្រសិនបើទឹកប្រាក់សង ការទូទាត់សង ឬឥណទានផ្តល់ជូនយើងខ្ញុំក្នុងរូបិយប័ណ្ណផ្សេងក្រៅពីរូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិក យើងខ្ញុំនឹងប្តូរប្រាក់នោះទៅជារូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិក នា ខណៈពេលដែលទទួលបានប្រាក់ទាំងនោះ និងតាមអត្រាប្តូរប្រាក់ ដែលយើងខ្ញុំកំណត់យកតាមឆន្ទានុសិទ្ធិសមស្របរបស់ខ្លួន។ លោកអ្នកត្រូវទទួលខុសត្រូវចំពោះរាល់ហានិភ័យនៃការប្តូរប្រាក់នេះដែលនឹងអាចកើតមានឡើងជាការខាតបង់ កម្រៃជើងសារ កម្រៃ និង ថ្លៃសេវាកម្ម។
   រាល់ប្រតិបត្តិការដកសាច់ប្រាក់ ដែលធ្វើឡើងតាមរយៈកាតឥណពន្ធរបស់លោកអ្នកនៅក្រៅប្រទេសកម្ពុជា នឹងបង្កើតឱ្យមានការទូទាត់ប្រាក់ដែលធ្វើឡើងដោយយើងខ្ញុំទៅកាន់លោកអ្នក និងការផ្ញើរប្រាក់ទៅកាន់ប្រទេសដែលប្រតិបត្តិការដកសាច់ប្រាក់ នោះត្រូវបានធ្វើឡើង។ សិទ្ធិរបស់លោកអ្នកក្នុងការធ្វើប្រតិបត្តិការដកសាច់ប្រាក់ នៅក្រៅប្រទេសត្រូវអនុលោមតាមច្បាប់ និងបទបញ្ញត្តិនៃប្រទេសកម្ពុជា និងច្បាប់នៃប្រទេសដែលលោកអ្នកធ្វើប្រតិបត្តិការដកសាច់ប្រាក់ ឬ ស្នើសុំឱ្យមានប្រតិបត្តិការដកសាច់ប្រាក់ (រួមបញ្ចូលដោយមិនកំណត់ រាល់ការគ្រប់គ្រងការប្តូរប្រាក់ បទបញ្ញត្តិ ឬ កម្រិតកំណត់ដែលមានអាទិភាពខ្ពស់ជាងនៅក្នុងប្រទេសនោះ)។
   នាកាលៈទេសៈណាមួយលោកអ្នកត្រូវទូទាត់សងដល់យើងខ្ញុំនូវរាល់ហានិភ័យនៃការប្តូរប្រាក់ ការខាតបង់ដែលកើតឡើងដោយសមហេតុផល ការទំនាក់ទំនង និងកម្រៃ និងថ្លៃសេវាកម្ម ដែលនឹងអាចកើតមាន។

## 6. របាយការណ៍គណនី និងឯកសារឆ្លើយឆ្លង

របាយការណ៍គណនីនឹងផ្តល់ជូនសម្រាប់គ្រប់គណនីទាំងអស់។ លោកអ្នកអាចសរសេរជាលាយល័ក្ខណ៍អក្សរ ដើម្បីស្នើសុំរបាយការណ៍គណនីរបស់លោកអ្នក និងរាល់សេចក្តីជូនដំណឹង ឯកសារឆ្លើយឆ្លង ឬឯកសារផ្សេងៗទៀតដែលបានចេញឱ្យដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ទាក់ទងទៅនឹងគណនីរបស់លោកអ្នក។ លោកអ្នកអាចទទួលយកឯកសារទាំងនេះពីសាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ណាមួយក៏បាន។

## 7. គណនីរួម

នៅពេលដែលគណនីរបស់លោកអ្នកមានម្ចាស់រួមគ្នាជាមួយនឹងមនុស្សម្នាក់ ឬ ច្រើននាក់ផ្សេងទៀត ចំនុចខាងក្រោមនេះត្រូវយកមកអនុវត្ត៖

(ក) ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចផ្តល់របាយការណ៍គណនី សេចក្តីជូនដំណឹងឯកសារឆ្លើយឆ្លង និងឯកសារផ្សេងៗ ទៀតទៅឱ្យបុគ្គលម្នាក់ដែលជាម្ចាស់គណនី។

(ខ) ប្រសិនបើធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ផ្ដល់របាយការណ៍គណនី សេចក្ដីជូនដំណឹង ឯកសារឆ្លើយឆ្លង និងឯកសារផ្សេងៗទៀតជូនទៅឱ្យបុគ្គលម្នាក់ដែលជាម្ចាស់គណនី ឯកសារទាំងនោះនឹងត្រូវបានចាត់ទុកថា ត្រូវបានប្រគល់ទៅឱ្យម្ចាស់គណនីរួចហើយ។

(គ) ប្រសិនបើម្ចាស់គណនីណាម្នាក់ស្លាប់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់នឹងចាត់ទុកសមតុល្យនៃគណនីនោះថា មានម្ចាស់រួមគ្នារវាងម្ចាស់គណនីដែលនៅរស់ និងអ្នកទទួលមរតកស្របច្បាប់ពីម្ចាស់គណនីដែលបានស្លាប់ ប្រសិនបើច្បាប់មិនតម្រូវឱ្យ ឬ អនុញ្ញាតឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ធ្វើអ្វីផ្សេងពីនេះ។ ប្រសិនបើអ្នកទទួលមរតក គឺជាមនុស្សតែមួយជាមួយនឹងម្ចាស់គណនីដែលនៅរស់ នោះម្ចាស់គណនីដែលនៅរស់នឹងក្លាយជាម្ចាស់គណនីតែម្នាក់គត់។

(ឃ) នៅក្នុងករណីចង់ផ្ដាច់ពីគណនីរួមនេះ មានតែម្ចាស់គណនីចម្បងម្នាក់គត់ ដែលមានសិទ្ធិសម្រេចផ្ដាច់ម្ចាស់គណនីចម្បង ឬម្ចាស់គណនីរងពីគណនីរួមនេះ។

(ង) សម្រាប់គណនីរួម ដែលត្រូវបានធ្វើឡើងតាមរយៈការចុះហត្ថលេខាពីម្ចាស់គណនីណាមួយ កាតឥណពន្ធដាច់ដោយឡែក និងលេខកូដសម្ងាត់ផ្ទាល់ខ្លួននឹងត្រូវផ្ដល់ជូនម្ចាស់គណនីនីមួយៗ។ ក៏ប៉ុន្តែ ម្ចាស់គណនីនីមួយៗត្រូវទទួលខុសត្រូវរួមគ្នាលើរាល់ប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធនឹងការប្រើប្រាស់កាតឥណពន្ធដែលត្រូវបានផ្ដល់ជូននោះ។ ក្នុងករណីដែលគណនីរួមទាមទារឱ្យមានការចុះហត្ថលេខាពីម្ចាស់គណនី ចំនួនពីរ ឬច្រើន ម្ចាស់គណនីទាំងនោះ មិនមានសិទ្ធិក្នុងការទទួលបានកាតឥណពន្ធ ចំពោះគណនីរួមនោះឡើយ។ សម្រាប់ម្ចាស់គណនីប្រភេទនោះនិងគណនីដែលបើកដោយនីតិបុគ្គលអាចទទួលបានកាតដែលភ្ជាប់ជាមួយមុខងារសម្រាប់តែសាកសួរព័ត៌មានតែប៉ុណ្ណោះ។ ចំពោះការបើកគណនីសម្រាប់ឯកបុគ្គលដែលកាតឥណពន្ធត្រូវបានផ្ដល់ជូនឯកបុគ្គលនោះត្រូវទទួលខុសត្រូវលើរាល់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងការប្រើប្រាស់កាតឥណពន្ធដែលបានផ្ដល់ជូន។

## 8. មូលប្បទានប័ត្រ និងមូលនិធិដែលបានផ្ទៀងផ្ទាត់រួច

ប្រាក់បញ្ញើមិនមែនជាសាច់ប្រាក់ (ដូចជាមូលប្បទានប័ត្រ និងប្រាក់បញ្ញើមិនទាន់រួចផ្សេងទៀត) នឹងមិនត្រូវបានដាក់បញ្ចូលទៅក្នុងគណនីរបស់លោកអ្នករហូតដល់មានការផ្ទៀងផ្ទាត់រួចរាល់ ហើយត្រូវធ្វើប្រតិបត្តិការដូចខាងក្រោមនេះ៖

នៅពេលដែលលោកអ្នកបង់មូលប្បទានប័ត្រចូលទៅក្នុងគណនីណាមួយតាមឆន្ទានុសិទ្ធិរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អនុញ្ញាតឱ្យលោកអ្នកធ្វើប្រតិបត្តិការលើមូល-ប្បទានប័ត្រមុនពេលធ្វើការផ្ទៀងផ្ទាត់ ហើយអាចតម្រូវឱ្យលោកអ្នកបង់កម្រៃសេវាកម្មដកប្រាក់ក្រោមសមតុល្យនៅលើមូលនិធិដែលមិនទាន់ផ្ទៀងផ្ទាត់រួច។ ប្រសិនបើមិនអាចផ្ទៀងផ្ទាត់បានទេ ប្រាក់បញ្ញើនឹងត្រូវដកចេញពីគណនីនោះវិញ ទោះបីជាប្រាក់បញ្ញើនោះត្រូវបានបញ្ចូលទៅក្នុងគណនីរួចរាល់ហើយក៏ដោយ ហើយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចតម្រូវឱ្យលោកអ្នកបង់កម្រៃសេវាកម្មដកប្រាក់លើសសមតុល្យ។

លោកអ្នកត្រូវតែជូនព័ត៌មានមកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឱ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន ប្រសិនបើលោកអ្នកសង្ស័យ ឬដឹងថាសៀវភៅមូលប្បទានប័ត្រលោកអ្នកបានបាត់បង់ ឬត្រូវបានលួច។ លោកអ្នកត្រូវទទួលខុសត្រូវលើប្រតិបត្តិការទាំងឡាយណាដែលកើតឡើងដោយសារភាពយឺតយ៉ាវរបស់លោកអ្នកក្នុងការជូនព័ត៌-មានមកកាន់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ទោះបីជាប្រតិបត្តិការនោះបានធ្វើឡើងដោយ

គ្មានការអនុញ្ញាតពីលោកអ្នកយ៉ាងណាក៏ដោយ។

ខ្ញុំ/យើងខ្ញុំ/អ្នកតំណាងក្រុមហ៊ុន ជាអ្នកចេញផ្សាយមូលប្បទានបត្រ យល់ព្រមឱ្យធនាគារបញ្ចូលព័ត៌មានមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី និងចែករំលែកព័ត៌មានទាំងនេះទៅឱ្យតតិយជន សម្រាប់គោលបំណងដូចមានចែងក្នុងប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន។

ខ្ញុំ/យើងខ្ញុំ/អ្នកតំណាងក្រុមហ៊ុន យល់ថា អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី និង ធនាគារ ទទួលខុសត្រូវលើការប្រមូល ការដាក់ឱ្យដំណើរការ និងការផ្សព្វផ្សាយទិន្នន័យ។ ខ្ញុំ/យើងខ្ញុំ/អ្នកតំណាងក្រុមហ៊ុន មានសិទ្ធិទទួលព័ត៌មាននិងទិន្នន័យរបស់យើងខ្ញុំ/ក្រុមហ៊ុនយើងខ្ញុំ និងមានសិទ្ធិតវ៉ា ដើម្បីស្នើសុំកែតម្រូវ ឬលុបចោលទិន្នន័យទាំងនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់ស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសស្តីពីការចែករំលែកព័ត៌មានឥណទាន។

## 9. ការកែប្រែថ្លៃសេវាកម្ម អត្រាការប្រាក់ និងលក្ខខណ្ឌ

លោកអ្នកយល់ព្រមថា៖

តាមឆន្ទានុសិទ្ធិរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ គឺអាចធ្វើការកែប្រែលក្ខខណ្ឌ ថ្លៃសេវាកម្ម និងអត្រាការប្រាក់ទាំងអស់នេះ ដែលអនុវត្តចំពោះគណនីរបស់លោកអ្នកគ្រប់ពេលទាំងអស់ និងរាល់ការកែប្រែលើលក្ខខណ្ឌ ថ្លៃសេវាកម្ម កម្រៃ និង/ឬអត្រាការប្រាក់ដែលអនុវត្តចំពោះគណនីរបស់លោកអ្នកនឹងត្រូវយកមកអនុវត្តភ្លាមៗ បន្ទាប់ពីលោកអ្នកបានទទួលសេចក្តីជូនដំណឹងស្តីពីការកែប្រែទាំងនោះ ឬត្រូវបានចាត់ទុកថាបានទទួលដំណឹងក្រោមលក្ខខណ្ឌទី 9 នេះ។

លោកអ្នកយល់ព្រមថាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចជូនដំណឹងដល់លោកអ្នកអំពីការប្រែប្រួលផ្សេងៗចំពោះថ្លៃសេវាកម្ម កម្រៃ និងអត្រាការប្រាក់ ឬលក្ខខណ្ឌទាំងនេះនៃគណនីរបស់លោកអ្នកដោយសេចក្តីជូនដំណឹងដែលត្រូវបានបង្ហាញខាងក្រោមនេះ៖

- (ក) បោះផ្សាយពីការកែប្រែនោះនៅក្នុងរបាយការណ៍គណនីរបស់លោកអ្នក ឬ
- (ខ) បង្ហាញពីការកែប្រែនោះនៅតាមសាខាធនាគាររបស់យើងខ្ញុំ ឬតាមម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ឬ
- (គ) ប្រកាសការកែប្រែ នៅលើគេហទំព័ររបស់យើងខ្ញុំ ឬ
- (ឃ) តាមសារអេឡិចត្រូនិក ឬសំបុត្រ ឬ
- (ង) បោះផ្សាយការកែប្រែនោះ តាមសារព័ត៌មាន ឬ
- (ច) តាមរយៈរាល់គ្រប់មធ្យោបាយទំនាក់ទំនងសមស្របដែលត្រូវបានកំណត់ដោយធនាគារយើងខ្ញុំ។

ក្រោយពីការបិទប្រកាសព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានទាំងនេះ លោកអ្នកត្រូវបានសន្មត់ថាបានទទួលព័ត៌មានទាំងនេះដោយស្វ័យប្រវត្តិ។

ប្រសិនបើលោកអ្នកបន្តរក្សា ឬប្រើប្រាស់កាតឥណពន្ធ និង/ឬសេវាកម្មអេឡិចត្រូនិកបន្ទាប់ពីទទួលបានការជូនដំណឹង លោកអ្នកនឹងត្រូវបានចាត់ទុកថាយល់ព្រមទទួលការកែប្រែនោះ។ ប្រសិនបើលោកអ្នកមិនទទួលការកែប្រែនោះទេ លោកអ្នកត្រូវបញ្ឈប់ការប្រើប្រាស់កាតឥណពន្ធ និង/ឬសេវាកម្មអេឡិចត្រូនិក និងបញ្ជាឱ្យយើងងខ្ញុំបញ្ចប់សេវាកម្មកាតឥណពន្ធ និង/ឬសេវាកម្មអេឡិចត្រូនិក។ ដើម្បីជៀសវាងនូវរាល់ចម្ងល់នានា ការបញ្ចប់នេះនឹងបញ្ចប់កម្មវិធីកាតដោយស្វ័យប្រវត្តិ។ ទោះបីជាមានការចែងខាងលើ យើងខ្ញុំអាចធ្វើការកែប្រែនានាក្នុងគោលបំណងរដ្ឋបាល ឬការបញ្ជាក់ដោយពុំចាំបាច់មានការជូនដំណឹងមុនទៅកាន់លោកអ្នក។

## 10. ការទទួលខុសត្រូវរបស់លោកអ្នកចំពោះប្រតិបត្តិការដែលគ្មានការអនុញ្ញាត

លោកអ្នកត្រូវទទួលខុសត្រូវលើគ្រប់ប្រតិបត្តិការទាំងអស់ ដែលកើតឡើងដោយសារការប្រើលេខសំងាត់ និង/ឬលេខកូដសុវត្ថិភាពដែលផ្តល់ជូនសំរាប់ប្រើជាមួយនឹងគណនីរបស់លោកអ្នក (ប្រតិបត្តិការអេឡិចត្រូនិក)។ ចំពោះប្រតិបត្តិការផ្សេងៗ ទៀត (មិនមែនជាប្រតិបត្តិការអេឡិចត្រូនិក) លោកអ្នកត្រូវទទួលខុសត្រូវចំពោះគណនីរបស់លោកអ្នកដូចខាងក្រោមនេះ៖

(ក) លោកអ្នកត្រូវពិនិត្យឡើងវិញ និងផ្ទៀងផ្ទាត់ព័ត៌មានផ្សេងៗ ទាក់ទងនឹងគណនីដែលបានបើកជាមួយនឹងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ក្នុង រយៈពេល 30 ថ្ងៃក្រោយពេលចុងខែនីមួយៗ (រយៈពេលផ្ទៀងផ្ទាត់គណនី) ហើយត្រូវជូនព័ត៌មានភ្លាមៗមកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ប្រសិនបើ៖

- មានការសង្ស័យថា បានកោស លុប ឬបានដកចេញខុសពីគណនី ឬ
- រាល់ប្រតិបត្តិការដែលមិនមានការអនុញ្ញាត ត្រូវបានធ្វើឡើងទាក់ទងនឹងគណនី

(ខ) លើកលែងតែក្នុងករណីដែល៖

- លោកអ្នកជូនព័ត៌មានមក ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ស្របតាមអនុប្រយោគ (ក)
- មានការដកចេញ ឬ ដាក់មិនត្រឹមត្រូវនូវកម្រៃសេវាដែលធ្វើឡើងដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬ
- ការខាតបង់ប្រយោជន៍របស់លោកអ្នកដែលបង្កឡើងដោយភាពមិនស្មោះត្រង់របស់បុគ្គលិកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬភ្នាក់ងារ ឬក្រុមហ៊ុនដែលពាក់ព័ន្ធជាមួយនឹងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬពាណិជ្ជករ ឬភ្នាក់ងារ របស់ពាណិជ្ជករនោះ ឬបុគ្គលិករបស់ពាណិជ្ជករនោះ។

ធនាគារ ជេ ត្រាស់ រ៉ូយាល់ មានសិទ្ធពេញលេញបន្ទាប់ពីផុតរយៈពេលផ្ទៀងផ្ទាត់នេះ ក្នុងការចាត់ទុកថារាល់កំណត់ត្រាទាំងអស់ ដែលមាននៅក្នុងរបាយការណ៍គណនីទាក់ទងនឹងប្រតិបត្តិការមិនមែនតាមប្រព័ន្ធអេឡិចត្រូនិកជាភស្តុតាងជាក់លាក់ដោយមិនចាំបាច់ត្រូវការភស្តុតាងអ្វីបន្ថែម ដើម្បីបញ្ជាក់ថាកំណត់ត្រាទាំងនោះ ត្រឹមត្រូវ និងគ្រប់គ្រាន់នោះឡើយ ហើយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ត្រូវរួចផុតពីការទាមទារទាំងឡាយណាទាក់ទិននឹងចំនួនទាំងនេះ។

(គ) លោកអ្នកត្រូវយកចិត្តទុកដាក់ និងមានការប្រុងប្រយ័ត្នឱ្យសមស្របដើម្បីការពារកុំឱ្យមានប្រតិបត្តិការដែលមិនមានការអនុញ្ញាត ឬមានការលួចក្លែងបន្លំកើតឡើងចំពោះគណនីរបស់លោកអ្នក ប៉ុន្តែមិនត្រូវបានកំណត់ដូចជា៖

- ប្រព័ន្ធផ្ទៀងផ្ទាត់ និងបែបបទដែលធ្វើឱ្យលោកអ្នកអាចកំណត់បាន ភ្លាមៗថាតើចំនួនទឹកប្រាក់ ដែលមិនមានការអនុញ្ញាតត្រូវបានដកចេញពីគណនីរបស់លោកអ្នក ឬយ៉ាងណា
- ការបញ្ជាក់ទៀងទាត់ពីប្រតិបត្តិការលើគណនីរបស់លោកអ្នក ជាប្រចាំដោយមនុស្សដែលមានសមត្ថភាព ឬមានបទពិសោធន៍គ្រប់គ្រាន់ល្មម
- ប្រសិនបើមិនមានការលំបាកក្នុងការអនុវត្តទេ ការបែងចែកភារកិច្ចសមស្រប គឺជាមនុស្សដែលទទួលខុសត្រូវចំពោះបញ្ហាដែលបានពិពណ៌នានៅក្នុងអនុប្រយោគ (ក) និង (គ) គឺជាមនុស្សដែលមិនមែនជាអ្នកទទួលខុសត្រូវលើការសរសេរ និង ឬការអនុញ្ញាតចំពោះប្រតិបត្តិការ។

ប្រសិនបើលោកអ្នកមិនធ្វើតាមការណែនាំខាងលើនេះទេ មានន័យថា លោកអ្នកទទួលយល់ព្រមថាលោកអ្នកគ្មានសិទ្ធិក្នុងការទាមទារអ្វីពីធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ទាក់ទងទៅនឹងការធ្វើប្រតិបត្តិការមិនមែនតាមប្រព័ន្ធអេឡិចត្រូនិកដែលគ្មានការអនុញ្ញាត ឬដោយមានការលួចបន្លំ។

## 11. ការរក្សាការសម្ងាត់

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងមិនប្រកាសអំពីព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ព័ត៌មានលម្អិតគណនី ឬប្រតិបត្តិការគណនី ឬព័ត៌មានណាមួយដែលទទួលបានពីលោកអ្នកដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ប្រាប់បុគ្គលណាម្នាក់នោះទេ។ ប្រធានបទមានដូចខាងក្រោមនេះ៖

លោកអ្នកយល់ព្រមថាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចប្រាប់ព័ត៌មានផ្ទាល់ខ្លួនលោកអ្នកទៅសមាជិករបស់ក្រុមធនាគារ ឬសាខារបស់ខ្លួនក្នុងគោលបំណងរៀបចំទិន្នន័យ និងកិច្ចការផ្សេងៗទៀតដែលមានការពាក់ព័ន្ធអ្នកផ្គត់ផ្គង់សេវាកម្ម ដែលមានទំនាក់ទំនងជាមួយនឹងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដើម្បីអនុវត្ត ឬជួយការងារ ឬសកម្មភាពផ្សេងៗរបស់ធនាគារនៅពេល ដែលការបង្ហាញឬការផ្តល់ព័ត៌មានទៅបុគ្គលណាម្នាក់ទៀត រួមមានភ្នាក់ងាររដ្ឋាភិបាល ឬអាជ្ញាធរ ប្រមូលចំណូល ទោះជាក្នុងស្រុក ឬបរទេស ដែលទាមទារដោយច្បាប់ក្នុងស្រុក ឬបរទេស និង/ឬធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានកិច្ចព្រមព្រៀងជាមួយភ្នាក់ងារនោះ។

លោកអ្នកយល់ព្រមថា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក (ប៉ុន្តែមិនមានព័ត៌មានលំអិតអំពីគណនីរបស់លោកអ្នក ឬការធ្វើ ប្រតិបត្តិការនៃគណនីរបស់លោកអ្នកទេ) ទៅឱ្យអង្គភាពណាមួយដែលមាន ទំនាក់ទំនងជាមួយនឹងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នៅក្នុងគោលបំណងផ្សព្វផ្សាយឬផ្តល់ទៅឱ្យអ្នកផ្តល់សេវាកម្មណាមួយដែលធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បានព្រមព្រៀងគ្នាក្នុងការធ្វើការស្ទង់មតិអតិថិជន ឬសំរាប់ការស្រាវជ្រាវពីអតិថិជន និងការស្វែងយល់ពីទីផ្សារ។ លោកអ្នកយល់ព្រមថា អ្នកផ្តល់សេវាកម្មរបស់ធនាគារជេ ត្រាស់ រ៉ូយ៉ាល់ អាចនឹងធ្វើការទាក់ទងជាមួយលោកអ្នកក្នុងគោលបំណងនោះ។ ធនាគារនឹងបង្ហាញព័ត៌មានដែលទាក់ទងទៅនឹងអតិថិជនរបស់ខ្លួនលុះត្រា តែធនាគារមានជំនឿដោយផ្អែកលើមូលដ្ឋានសមរម្យថា អ្នកទទួលព័ត៌មាននឹងរក្សាការសំងាត់ដូចធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ដែរ។

លោកអ្នកយល់ព្រមថារាល់ការផ្តល់ព័ត៌មានក្នុងករណីដូចបានរៀបរាប់ខាងលើ ដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អ្នកគ្រប់គ្រង អ្នកចាត់ចែង បុគ្គលិក ឬមនុស្សផ្សេងទៀតននឹងមិនត្រូវចាត់ទុកថាជាការរំលោភលើច្បាប់ ឬកាតព្វកិច្ចភាពសម្ងាត់នៃវិជ្ជាជីវៈនោះឡើយ។

## 12. ការរំខានដល់សេវាកម្ម

លោកអ្នកយល់ព្រមថាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងមិនទទួលខុសត្រូវលើការខាតបង់ ឬ ខូចខាតដែលកើតឡើងដោយសេវាកម្មបណ្តោះអាសន្ន ឬនៅពេលដែលប្រព័ន្ធ ឬឧបករណ៍ដំណើរការមិនប្រក្រតី។

## 13. ការផ្តល់ឥណទាន

ក្នុងករណី ដែលមិនមានកិច្ចព្រមព្រៀងជាក់លាក់ក្នុងការផ្តល់ឥណទានទាក់ទង នឹងគណនីរបស់លោកអ្នក (ឧ.តាមរយៈការផ្តល់ឥណទានលើសសមតុល្យ) ប្រសិន បើលោកអ្នកស្នើសុំដកប្រាក់ ឬទូទាត់ប្រាក់ចេញពីគណនីរបស់លោកអ្នកដែលលើសពីចំនួនទឹកប្រាក់ដែល មានក្នុងគណនីរបស់លោកអ្នកតាមឆន្ទានុសិទ្ធិ របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចអនុញ្ញាតឱ្យដកប្រាក់តាមលក្ខខណ្ឌខាងក្រោម៖

(ក) លោកអ្នកត្រូវបង់ការប្រាក់តាមអត្រាការប្រាក់កម្ចីមូលដ្ឋាន (Based

Lending Rate) របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បូកបន្ថែម 20% ទៀត គិតទៅលើចំនួនទឹកប្រាក់ដែលបានដកលើសសមតុល្យ

(ខ) ក្នុងករណីដែលធនាគារយល់ព្រមឱ្យមានការដកប្រាក់លើសសមតុល្យដែលមាននៅក្នុងគណនីលោកអ្នកត្រូវបង់កម្រៃដកប្រាក់លើសសមតុល្យតាមការកំណត់របស់ធនាគារ (សូមមើលសេចក្ដីលម្អិតនៅក្នុងកូនសៀវភៅ ដែលនិយាយពីថ្លៃសេវាកម្ម និងកម្រៃរបស់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់)

(គ) ធនាគារនឹងគិតការប្រាក់ និងកម្រៃសេវាកម្មផ្សេងៗដែលពាក់ព័ន្ធនឹងការដកលើសនេះចេញពីគណនីរបស់លោកអ្នក និង

(ឃ) ចំនួនទឹកប្រាក់ ដែលបានដកលើសការប្រាក់ដែលបានគិតលើចំនួនដែលដកលើស និងថ្លៃឈ្នួលដែលដកលើស ត្រូវទូទាត់សងវិញនៅរយៈពេល7ថ្ងៃបន្ទាប់ពីចំនួននោះត្រូវកត់ត្រាក្នុងផ្នែកឥណពន្ធនៅក្នុងគណនីរបស់លោកអ្នក។

## 14. ការប្រឆាំងការលាងលុយ ភេរវកម្មហិរញ្ញវត្ថុ និងការត្រួតពិនិត្យហិរញ្ញវត្ថុ

លោកអ្នកយល់ព្រមថា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចនឹងពន្យាពេលឬបដិសេធមិនធ្វើប្រតិបត្តិការណាមួយដោយមិនទទួលខុសត្រូវអ្វីទាំងអស់ ប្រសិនបើធនាគារមានមន្ទិលសង្ស័យ៖

(ក) ប្រតិបត្តិការអាចរំលោភលើច្បាប់ ឬបទបញ្ញត្តិណាមួយនៅក្នុងប្រទេសកម្ពុជា ឬប្រទេសណាផ្សេងទៀត។

(ខ) ប្រតិបត្តិការដែលជាប់ពាក់ព័ន្ធនឹងអង្គភាពណាមួយ (បុគ្គល សហជីព ឬ រដ្ឋាភិបាល) ដែលមានទណ្ឌកម្ម ឬជាប់ពាក់ព័ន្ធគ្នាដោយផ្ទាល់ ឬ ដោយប្រយោលចំពោះបុគ្គលដែលមានទណ្ឌកម្មស្ថិតក្រោមទណ្ឌកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដែលកំណត់ដោយសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ឬ ប្រទេសដទៃ។

(គ) ប្រតិបត្តិការដែលអាចទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងមូលនិធិ ដែលទទួលបានដោយខុសច្បាប់ក្នុងប្រទេសកម្ពុជា ឬ ប្រទេសដទៃ។

លោកអ្នកត្រូវផ្តល់ព័ត៌មានទាំងអស់មកឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ តម្រូវឱ្យមានការលាងលុយភេរវកម្មហិរញ្ញវត្ថុ ឬទណ្ឌកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្ម ឬដើម្បីអនុលោមទៅតាមច្បាប់ ឬបទ បញ្ញត្តិនានា នៅក្នុងប្រទេសកម្ពុជា ឬប្រទេសដទៃ ឬគោរពតាមការចាត់ចែង ការស្នើសុំ ឬតម្រូវការ (មាន ឬមិនមានក្នុងច្បាប់) ដោយរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត។ លោកអ្នកយល់ព្រមថាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចបង្ហាញព័ត៌មានអតិថិជនដល់៖

(ក) ភ្នាក់ងារអនុវត្តច្បាប់តុលាការ ឬនិយ័តករដែលតម្រូវដោយច្បាប់ ឬបទបញ្ញត្តិនៅក្នុងប្រទេសកម្ពុជា ឬប្រទេសដទៃទៀត និង

(ខ) ឯកសារដែលទាក់ទងជាមួយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ប្រើប្រាស់ដើម្បីធ្វើការទូទាត់សម្រាប់គោលបំណងនៃច្បាប់ ឬបទបញ្ញត្តិណាមួយ

(គ) ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬសមាជិកក្រុមណាមួយ ដែលតម្រូវឱ្យស្របតាមការចាត់តាំងស្នើសុំ ឬតម្រូវការ (មាន ឬមិនមាននៅក្នុងច្បាប់) ដោយរដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសណាមួយ និង

(ឃ) ទៅកាន់សមាជិកក្រុម ឬអ្នកផ្តល់សេវាកម្មរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដើម្បីការងាររដ្ឋបាល និងប្រតិបត្តិ (ដោយរាប់បញ្ចូលទាំងការគ្រប់គ្រងហានិភ័យបំណុលដែលទូទាត់បានមកវិញការផ្សព្វផ្សាយ ដំណើរការទិន្នន័យ ប្រព័ន្ធនៃការអភិវឌ្ឍន៍ និងសាកល្បងការកត់ត្រាលើឥណទាន ការបណ្តុះ

បណ្តាលបុគ្គលិក ផ្នែកទីផ្សារនិងការស្វែងយល់ពីតម្រូវការរបស់អតិថិជន)។

លុះត្រាលោកអ្នកបានបញ្ជាក់ប្រាប់ជាមុនថា លោកអ្នកធ្វើឡើងក្នុងនាមជាអ្នកដែលត្រូវផ្តល់ការទុកចិត្ត ឬជាភាគីផ្សេងទៀត បើមិនដូច្នោះទេ មានន័យថា លោកអ្នក និងតំណាងដែលទទួលបានសិទ្ធិពីលោកអ្នកបានធ្វើអ្វីៗក្នុងនាមលោកអ្នក ក្នុងការចុះកិច្ចសន្យាព្រមព្រៀងនេះ។

លោកអ្នកយល់ព្រមទទួលខុសត្រូវចំពោះធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ថារាល់ដំណើរការប្រតិបត្តិការទាំងអស់ជាមួយ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងមិនរំលោភលើច្បាប់ ឬបទបញ្ញត្តិណាមួយរបស់ប្រទេសកម្ពុជា ឬ ច្បាប់របស់ប្រទេសណាមួយផ្សេងទៀតឡើយ។

## 15. ការប្តូរឈ្មោះ និងអាសយដ្ឋានដោយហត្ថលេខី

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងមិនទទួលខុសត្រូវចំពោះកំហុស ឬការបាត់បង់ណាមួយ ដែលទាក់ទងទៅនឹងការផ្លាស់ប្តូរខុសពីព័ត៌មានលម្អិតនៃគណនីរបស់លោកអ្នក ប្រសិនបើធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មិនបានទទួលសេចក្តីជូនដំណឹងជាមុននោះទេ។

## 16. សិទ្ធិរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ក្នុងការបញ្ចូលគណនីជាគណនីតែមួយ

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចដាក់បញ្ចូលសមតុល្យទឹកប្រាក់នៃគណនីរបស់លោកអ្នកដែលមានចំនួនពីរ ឬច្រើនជាងពីរគណនីមកជាគណនីតែមួយទោះបីជា គណនីទាំងនោះត្រូវបានបើកនៅតាមសាខាផ្សេងពីគណនីរួម ឬ ក្រោមរូបិយប័ណ្ណផ្សេងគ្នាក៏ដោយ។ ករណីនេះអាចកើតឡើង នៅពេលដែលលោកអ្នកដកប្រាក់លើសពីសមតុល្យអវិជ្ជមាន ហើយគណនីផ្សេងទៀតមានសមតុល្យវិជ្ជមាន មានន័យថា សមតុល្យគណនីមួយ អាចត្រូវបានយកទៅប្រើប្រាស់បង់សងសមតុល្យគណនីមួយផ្សេងទៀតដែលបានបើកក្នុងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។ ប្រសិនបើគណនីដែលត្រូវដាក់បញ្ចូលគ្នារបស់លោកអ្នកបានបើកក្រោមរូបិយ ប័ណ្ណផ្សេងគ្នា ធនាគារនឹងធ្វើការផ្លាស់ប្តូរទៅជារូបិយប័ណ្ណមួយតាមបែបបទស្តង់ដារនៃការប្តូរប្រាក់។

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងផ្តល់ព័ត៌មានជូនលោកអ្នកភ្លាម ប្រសិនបើគណនីលោកអ្នកត្រូវបានដាក់បញ្ចូលគ្នា។ ធនគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងមិនជូនដំណឹងដល់លោកអ្នកជាមុនទេ។ លោកអ្នកមិនគួរសន្មតថា គណនីរបស់លោកអ្នកត្រូវបានដាក់បញ្ចូលគ្នាទេ លុះត្រាតែធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ យល់ព្រមការរៀបចំនេះ។

## 17. រូបិយប័ណ្ណ

លើកលែងតែធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ យល់ព្រមអ្វីផ្សេងពីនោះ រាល់ការទូទាត់ប្រាក់ទាំងអស់ដែលបានធ្វើស្របតាមកិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជារូបិយប័ណ្ណដែលបានបង្ហាញនៅក្នុងគណនីរបស់លោកអ្នក។

ប្រសិនបើគណនីណាមួយរបស់លោកអ្នកបានបើកជាគណនីរូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិក ហើយច្បាប់បទបញ្ញត្តិ ឬគោលការណ៍ណែនាំចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជាតម្រូវដោយផ្ទាល់ ឬដោយប្រយោល ឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ប្តូរគណនីដែលប្រើដុល្លារអាមេរិកនោះឱ្យទៅជាគណនីដែលប្រើប្រាក់រៀល ឬ រូបិយប័ណ្ណផ្សេងទៀត។

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានសិទ្ធិក្នុងការប្តូរគណនី ពីគណនីរូបរូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិក។ វិធីសាស្ត្រដែលអនុវត្តសម្រាប់ការប្តូររូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយផ្សេងទៀតស្របតាមស្តង់ដារសម្រាប់ការប្តូររូបិយប័ណ្ណរបស់ធនាគារ។

## 18. ចំនួនទឹកប្រាក់ដែលជំពាក់

លោកអ្នកផ្តល់សិទ្ធិឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ធ្វើប្រតិបត្តិការឥណពន្ធនៅលើគណនីណាមួយរបស់លោកអ្នកដើម្បីទូទាត់៖

(ក) ចំនួនទឹកប្រាក់សរុបត្រូវបង់ និងបំណុល (រួមទាំងកម្រៃជើងសារ ថ្លៃសេវាកម្ម ការប្រាក់ ការចំណាយ ប្រាក់សំណង) ដែលលោកអ្នកបានជំពាក់ ឬក៏ត្រូវបង់ជូនធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និង

(ខ) ចំនួនទឹកប្រាក់សរុបដែលលោកអ្នកបានជំពាក់ ឬត្រូវបង់ជូនធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ទោះបីជា ឬក៏មិនអាស្រ័យលើចំនួនទូទាត់លើសណាមួយនៃគណនីណាមួយរបស់លោកអ្នកដែលកើតឡើងដោយសារកំហុស ឬការលុបចោលខាងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬផ្សេងពីនេះ។

## 19. ការបិទគណនីធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នក

លោកអ្នក ឬ អ្នកដែលទទួលបានសិទ្ធិពីលោកអ្នកអាចបិទគណនីរបស់លោកអ្នកបានគ្រប់ពេលវេលាតាមសំណើសុំនៅតាមសាខាណាមួយនៃធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដោយគោរពតាមសៀវភៅ "កម្រៃ និងថ្លៃសេវាកម្មរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់" ចំពោះករណីមួយចំនួនក្នុងការបិទគណនីមុនកាលកំណត់។

សៀវភៅសមតុល្យគណនី សៀវភៅមូលប្បទានប័ត្រ ឬកាតអេឡិចត្រូនិកនៃ គណនីរបស់លោកអ្នក ដែលមិនទាន់ប្រើប្រាស់ត្រូវប្រគល់ជូនធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ វិញនៅពេលដែលបិទគណនីរបស់លោកអ្នក។ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងទូទាត់ជាមួយលោកអ្នកនូវទឹកប្រាក់ដែលមាននៅក្នុងគណនីបូកបន្ថែមការប្រាក់ ប្រសិនបើមានហើយ ដកថ្លៃសេវាកម្មសរុបនៃគណនីដែលបានគរទុក និងកម្រៃផ្សេងៗសម្រាប់រដ្ឋាភិបាលដែលត្រូវបង់នៅថ្ងៃបិទគណនី។ កម្រៃត្រូវបង់ប្រចាំខែនឹងត្រូវយកមកអនុវត្តទោះបីជាគណនីត្រូវបានបើកក្នុងថ្ងៃណាមួយក្នុងអំឡុងខែក៏ដោយ។ រាល់មូលនិធិទាំងឡាយណាដែលមិនទាន់បានទូទាត់រួចនឹងមិនប្រគល់ឱ្យទេ រហូតដល់មូលនិធិនោះត្រូវបានទូទាត់សព្វគ្រប់។ គណនីដែលប្រើមូលប្បទានប័ត្រអាចត្រូវបានបិទ បន្ទាប់ពីមូលប្បទានប័ត្រដែលមិនទាន់ទូទាត់រួចត្រូវបានបង្ហាញ។ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ រក្សាសិទ្ធិក្នុងការបដិសេធនូវមូលប្បទានប័ត្រសម្រាប់ការទូទាត់ប្រាក់ក្រោយពេលគណនីត្រូវបានបិទ។

ប្រសិនបើគណនីរបស់លោកអ្នកមានសមតុល្យសូន្យ ឬអវិជ្ជមាន ហើយគ្មានការធ្វើប្រតិបត្តិការ (លើកលែងតែកម្រៃ និងសោហ៊ុយសម្រាប់រដ្ឋាភិបាល) លើសពីមួយខែ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចបិទគណនីរបស់លោកអ្នក។ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានឆន្ទានុសិទ្ធិរបស់ខ្លួនអាចបិទគណនីដោយសារតែមានការប្រព្រឹត្ត ដែលមានលក្ខណៈមិនសមស្រប ឬ នៅពេលដែលលោកអ្នកមិនបានផ្តល់ជូនធនាគារយើងខ្ញុំនូវព័ត៌មានដែលយើងខ្ញុំបានស្នើសុំយោងតាមលក្ខន្តិកៈនេះ ឬនៅពេលដែលមានការទាមទារដោយច្បាប់ក្នុងស្រុក ឬបរទេសនីយតករ ភ្នាក់ងាររដ្ឋាភិបាល ឬអជ្ញាធរប្រមូលចំណូល (ទោះបីក្នុងស្រុក ឬ បរទេស) ដោយសារតែមូលហេតុអ្វីផ្សេងទៀតដែលចាត់ទុកថាសមស្រប។

ចំពោះហេតុការណ៍នេះ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងជូនព័ត៌មានដល់លោកអ្នកតាមទូរស័ព្ទ ឬ ជាលាយល័ក្ខណ៍អក្សរតាមអាសយដ្ឋានដូចដែលបានបង្ហាញក្នុងឯកសារ ហើយនឹងចេញមូលប្បទានប័ត្រសម្រាប់ទឹកប្រាក់សរុបដែលនៅសល់ក្នុងគណនី ដែលលោកអ្នកអាចទូទាត់ជាសាច់ប្រាក់នៅតាមសាខាដែលរក្សាទុកគណនីរបស់លោកអ្នក។

ក្នុងករណីបិទគណនីរួមរបស់លោកអ្នក ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងបិទទៅតាមការណែនាំដែលផ្តល់ជូនដោយលោកអ្នកមកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នាពេលបើកគណនីរួម។

### 19.1. ការបិទគណនីនៅស្ងៀម ឬគ្មានសកម្មភាព

គណនីទាំងឡាយណាដែលមិនមានប្រតិបត្តិការក្នុងអំឡុងរយៈពេលលើសពីដប់ពីរ

(១២) ខែ នឹងត្រូវចាត់ទុកថាគណនីនៅស្ងៀម ឬ គ្មានសកម្មភាព។

ដូចនេះប្រសិនបើគណនីណាមួយ ឬទាំងអស់របស់លោកអ្នក គ្មានសមតុល្យ ឬ អវិជ្ជមានហើយគ្មានប្រតិបត្តិការលើសពីដប់ពីរ (១២) ខែ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងធ្វើការបិទគណនីទាំងនោះដោយពុំចាំបាច់មានការជូនដំណឹងដល់អតិថិជនជាមុនឡើយ។

### 19.2. ការបិទគណនីនៅស្ងៀម ឬគ្មានសកម្មភាពក្នុងរយៈពេលដប់ (១០) ឆ្នាំជាប់គ្នា

ប្រសិនបើគណនីណាមួយ ឬទាំងអស់របស់លោកអ្នកមានសមតុល្យ ហើយមិនមានប្រតិបត្តិការរយៈពេលដប់ (១០) ឆ្នាំជាប់គ្នា នោះរាល់សមតុល្យទាំងអស់នឹងត្រូវផ្ទេរទៅធនាគារជាតិនៃកម្ពុជាដែលជាអ្នកទទួលបន្ទុកគ្រប់គ្រងបន្ត (គណនីប្រាក់បញ្ញើ)។ ក្នុងករណីនេះធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់នឹងព្យាយាមទាក់ទងលោកអ្នក មុននឹងផ្ទេរសមតុល្យគណនីប្រាក់បញ្ញើរបស់លោកអ្នកទៅធនាគារជាតិនៃកម្ពុជា។ បន្ទាប់ពីសមតុល្យប្រាក់បញ្ញើរបស់លោកអ្នកត្រូវបានផ្ទេររួចរាល់ លោកអ្នកអាចទាក់ទង នាយកដ្ឋានប្រតិបត្តិការ និងគ្រប់គ្រងសាច់ប្រាក់នៃធនាគារជាតិនៃកម្ពុជាដោយផ្ទាល់ប្រសិនបើលោកអ្នកត្រូវការជំនួយបន្ថែម។

## 20. លក្ខខណ្ឌច្បាស់លាស់សំរាប់ប្រាក់បញ្ញើមានកាលកំណត់

ប្រសិនបើលោកអ្នកចង់ដកប្រាក់ទាំងអស់ ឬមួយផ្នែកចេញពីគណនីប្រាក់បញ្ញើ មានកាលកំណត់របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មុនថ្ងៃកំណត់ លោកអ្នកត្រូវស្នើសុំមកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ជាលាយល័ក្ខណ៍អក្សរ។ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានសិទ្ធិកាត់ចំនួនការប្រាក់ដែលត្រូវទូទាត់ជូន និងគិតកម្រៃពិន័យសំរាប់ការដកប្រាក់លឿន មុនកាលកំណត់ចេញពីគណនីប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។ ការប្រាក់មិនត្រូវគិតជូនបន្តបន្ទាប់ពីគណនីប្រាក់បញ្ញើមានកាលកំណត់របស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ត្រូវបានដកមុនកាលកំណត់។

## 21. សេវាកម្មភាគីទី3

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មិនផ្តល់សិទ្ធិលើកទឹកចិត្តឱ្យមានការគាំទ្រ ឬទទួលខុសត្រូវលើការប្រើប្រាស់សេវាកម្មគណនី ដែលផ្តល់ដោយភាគីទី3 ទៅលើគណនីលោកអ្នកឡើយ (រួមទាំងសេវាកម្មគណនីសរុប ដែលត្រូវបានផ្តល់ឱ្យដោយវិទ្យាស្ថានហិរញ្ញវត្ថុដទៃទៀត)។

## 22. សំណង

លោកអ្នកយល់ព្រមសងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ចំពោះការខាតបង់ ការចំណាយ ឬការខូចខាតផ្សេងៗ ដែលធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បានជួបប្រទះដោយសារតែការទាមទារតម្រូវការ ឬវិធានការណាមួយដែលបានធ្វើចំពោះធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលដោយសារតែលោកអ្នក៖

- (ក) មិនបានបំពេញតាមកាតព្វកិច្ចរបស់លោកអ្នកសមស្របតាមលក្ខខណ្ឌទាំងនេះ ឬ
- (ខ) បានប្រព្រឹត្តិដោយភាពធ្វេសប្រហែស ឬ ដោយក្លែងបន្លំទាក់ទងទៅនឹងគណនីរបស់លោកអ្នក។

លោកអ្នកយល់ព្រម សងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នូវរាល់ថ្លៃសេវាកម្មកម្រៃ ឬតម្លៃផ្សេងៗ ដែលផ្តល់ឱ្យដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលទាក់ទងនឹងគណនីនេះ។

## 23. សេចក្តីជូនដំណឹង និងការព្រមព្រៀង

ដរាបណាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មិនបានព្រមព្រៀងអ្វីផ្សេងពីនេះទេនោះ៖

(ក) រាល់ការចាត់តាំងតំណាង និងសេចក្តីជូនដំណឹងធ្វើឡើងដោយ លោកអ្នកដែលទាក់ទងនឹងគណនីរបស់លោកអ្នក ឬ លក្ខខណ្ឌទាំងនេះអាចមានសុពលភាព លុះត្រាធ្វើឡើងជាលាយលក្ខណ៍អក្សរ និងបញ្ជូនដល់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និង

(ខ) រាល់ការព្រមព្រៀងណាមួយរវាងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងលោកអ្នកទាក់ទងនឹងលក្ខខណ្ឌទាំងនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរដើម្បីឱ្យមានសុពលភាព។

## 24. លក្ខខណ្ឌនៃការប្រើប្រាស់សេវាកម្មធនាគារអេឡិចត្រូនិក

លក្ខខណ្ឌទាំងនេះត្រូវបានអនុវត្តចំពោះប្រតិបត្តិការអេឡិចត្រូនិកទាំងអស់។

### 24.1. កម្រិតនៃកាតឥណពន្ធ

យើងខ្ញុំអាចកំណត់ពីកម្រិតនៃការចំណាយដែលពាក់ព័ន្ធនឹងគណនីរបស់លោកអ្នក ដោយយើងខ្ញុំអាចកែប្រែ ដោយពុំមានការជូនដំណឹង។ យើងខ្ញុំអាចកំណត់កម្រិតនៃការចំណាយផ្សេងៗគ្នាសម្រាប់ប្រតិបត្តិការដោយប្រើប្រាស់កាតដែលផ្អែកលើហត្ថលេខា ប្រតិបត្តិការកាតដែលផ្អែកលើលេខកូដសម្ងាត់ផ្ទាល់ខ្លួន និងប្រតិបត្តិការមិនបង្ហាញកាត។

យើងខ្ញុំអាចលុបចោល ឬផ្អាកគណនីរបស់លោកអ្នកចំពោះរាល់ប្រតិបត្តិការដែលកើតមានឡើងនៅថ្ងៃដែលប្រតិបត្តិការនោះមានវត្តមានចំពោះយើងខ្ញុំក្នុងការទូទាត់សង ឬនៅថ្ងៃដែលយើងខ្ញុំទទួលបានការជូនដំណឹងពីប្រតិបត្តិការនោះ។ ចំពោះចំនួនទឹកប្រាក់ដែលត្រូវបានលុបចោល ឬផ្អាកនោះគឺគ្រាន់តែជាចំនួនសរុបប៉ាន់ប្រមាណនៃប្រតិបត្តិការជាក់ស្តែងប៉ុណ្ណោះ ហើយដែលចំនួននោះអាចនឹងមិនស្មើគ្នាជាមួយនឹងប្រតិបត្តិការជាក់ស្តែង។ យើងខ្ញុំមានសិទ្ធិក្នុងការបង្កើននូវចំនួនទឹកប្រាក់ដែលយើងខ្ញុំកាន់កាប់ពាក់ព័ន្ធនឹងរាល់ប្រតិបត្តិការដោយប្រើប្រាស់កាតនានាដែលមានប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីរូបិយប័ណ្ណដុល្លារអាមេរិកនាពេលណាមួយ ប្រសិនបើយើងខ្ញុំយល់ឃើញថា ចំនួនទឹកប្រាក់កាន់កាប់ដំបូងដែលត្រូវប្តូរទៅជារូបិយប័ណ្ណបរទេសមិនគ្រប់គ្រាន់ក្នុងការទូទាត់សងពេញលេញនូវប្រតិបត្តិការដោយប្រើប្រាស់កាតនោះ។ ប្រសិនបើយើងខ្ញុំលុបចោល ឬផ្អាកចំនួនទឹកប្រាក់ណាមួយ សមតុល្យដែលមាននៅក្នុងគណនីរបស់លោកអ្នក នឹងត្រូវបានកាត់តាមចំនួនទឹកប្រាក់ ដែលយើងខ្ញុំបានលុបចោល។ លោកអ្នកមិនអាចបញ្ឈប់ការទូទាត់សងលើប្រតិបត្តិការនោះ ឬការប្រើប្រាស់នូវទឹកប្រាក់សរុបដែលត្រូវបានលុបចោលដោយយើងខ្ញុំនោះឡើយ។ យើងខ្ញុំអាចលុបចោល ឬ ផ្អាកនូវចំនួនទឹកប្រាក់នោះរហូតដល់រយៈពេល 30ថ្ងៃ បន្ទាប់មកយើងខ្ញុំនឹងដកចេញពីគណនីរបស់លោកអ្នកនូវចំនួនទឹកប្រាក់ពេញលេញ នៃប្រតិបត្តិការជាក់ស្តែង។

លោកអ្នកអាចធ្វើប្រតិបត្តិការដោយប្រើប្រាស់កាតបាន ប្រសិនបើមានមូលនិធិគ្រប់គ្រាន់នៅក្នុងគណនីរបស់លោកអ្នកក្នុងការទូទាត់សងនូវប្រតិបត្តិការនោះ ហើយតម្រៃសរុបដែលកើតមានឡើងតាមគណនីរបស់លោកអ្នក មិនអាចលើសកម្រិតចំណាយដែលយើងខ្ញុំបានកំណត់សម្រាប់គណនីរបស់លោកអ្នកឡើយ។ លោកអ្នកមិនត្រូវធ្វើ ឬប៉ុនប៉ងធ្វើប្រតិបត្តិការដោយប្រើប្រាស់កាតណាដែលអាចធ្វើឱ្យលើសកម្រិត នៃការចំណាយរបស់លោកអ្នកឡើយ។ យើងខ្ញុំអាចបដិសេធក្នុងការអនុញ្ញាតលើប្រតិបត្តិការដែលលោកអ្នកមានបំណងចង់ធ្វើ ទោះបីជាប្រតិបត្តិការនោះនឹងមិនបណ្តាលឱ្យលើសកម្រិតចំណាយរបស់លោកអ្នកក៏ដោយ។

តាមឆន្ទានុសិទ្ធិរបស់យើងខ្ញុំ និងដោយពុំចាំបាច់មានការជូនដំណឹងជាមុនលើការយល់ព្រម យើងខ្ញុំអាចផ្តល់សិទ្ធិ ឬអនុញ្ញាតសិទ្ធិលើប្រតិបត្តិការដោយប្រើប្រាស់កាតអោយមានសុពលភាពក្នុងអំឡុងពេលណាមួយ ទោះបីជាប្រតិបត្តិការដោយប្រើប្រាស់

កាតនោះអាចនឹងបណ្តាលអោយគណនីរបស់លោកអ្នកមានសមតុល្យ អវិជ្ជមាន និង/ឬ លើសចំនួនកម្រិតចំណាយក៏ដោយ។ ការកំណត់របស់យើងខ្ញុំក្នុងការបញ្ជាក់ថាកម្រិតចំណាយរបស់លោកអ្នកត្រូវបានលើសនឹងត្រូវជាការកំណត់សរុបចុងក្រោយនិងមានអានុភាពអនុវត្តចំពោះលោកអ្នក។

## ចំនួនទឹកប្រាក់កំណត់នៃការដកប្រាក់ប្រចាំថ្ងៃ

លើកលែងតែលោកអ្នកបានស្នើសុំធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដើម្បីបន្ថែម ឬបន្ថយចំនួនកំណត់នៃទឹកប្រាក់របស់លោកអ្នក នោះចំនួនកំណត់បញ្ចូលគ្នានៃទឹកប្រាក់ប្រចាំថ្ងៃ ដែលអ្នកអាចប្រើប្រាស់តាមម៉ាស៊ីន ATM សម្រាប់កាតឥណពន្ធវីសា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ចំនួន 2,000 ដុល្លារអាមេរិក និងសម្រាប់កាតឥណពន្ធ វីសា Premier ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានចំនួន 4,000 ដុល្លារអាមេរិក។ នេះមានន័យថាលោកអ្នកអាចប្រើ កាតឥណពន្ធវីសា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នកដកប្រាក់សរុបចំនួន 2,000 ដុល្លាអាមេរិក ឬក៏ប្រើកាត ឥណពន្ធវីសា Premier ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នកដកប្រាក់សរុបបានចំនួន 4,000 ដុល្លាអាមេរិក ក្នុងមួយថ្ងៃពីគណនីរួមនានា របស់លោកអ្នកក្នុងករណីដែលគណនីនោះមានតុល្យភាពគ្រប់គ្រាន់។

### 24.2. សុពលភាព និងកាលបរិច្ឆេទផុតកំណត់របស់កាតឥណពន្ធ

ទោះក្នុងកាលៈទេសៈណាក៏ដោយកាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នក គឺជាកម្មសិទ្ធិរបស់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ជានិច្ច។ លោកអ្នកមិនអាចផ្ទេរ ឬ បែងចែកការគ្រប់គ្រង ការថែរក្សា ឬការកាន់កាប់ជាកម្មសិទ្ធិលើកាតនោះឡើយ។ យើងខ្ញុំអាចស្នើសុំឱ្យលោកអ្នកប្រគល់កាតមកវិញនាពេលណាមួយក៏ដោយតាមឆន្ទានុសិទ្ធិសមស្របរបស់យើងខ្ញុំ ហើយលោកអ្នកត្រូវប្រគល់កាតមកយើងខ្ញុំវិញជាបន្ទាន់។ កាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ត្រូវតែចុះហត្ថលេខាភ្លាមៗដោយអ្នកប្រើប្រាស់កាតដែលធនាគារផ្តល់ជូន ហើយកាតនេះអាចប្រើប្រាស់បានតែចន្លោះ “មានសុពលភាព” និង “រហូតដល់” ដែលបានបញ្ជាក់នៅលើកាត។ ដើម្បីជានាសុវត្ថិភាព លោកអ្នកត្រូវកាត់កាតជាពីរតាមខ្សែអង្កត់ទ្រូងភ្លាម នៅពេលកាតឥណពន្ធរបស់លោកអ្នកអស់សុពលភាព។

កាតឥណពន្ធមិនអាចត្រូវបានផ្ទេរ ហើយកាតឥណពន្ធអាចប្រើប្រាស់បានដោយបុគ្គលដែលយើងខ្ញុំផ្តល់កាតឥណពន្ធនោះជូន និងបុគ្គលដែលមានឈ្មោះនៅលើកាតឥណពន្ធក្នុងកំឡុងពេលដែលកាតមានសុពលភាពតែប៉ុណ្ណោះ។ ពុំមានបុគ្គលដទៃណាមួយត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កាតឥណពន្ធ និង/ឬ លេខកូដសម្ងាត់ផ្ទាល់ខ្លួនដើម្បីធ្វើប្រតិបត្តិការដោយប្រើប្រាស់កាតណាមួយឡើយ។ សេវាកម្ម មុខងារ និងឧបករណ៍ដែលមានតាមរយៈការប្រើប្រាស់លេខកូដសម្ងាត់ផ្ទាល់ខ្លួននៃកាតឥណពន្ធ ត្រូវបានកំណត់ដោយយើងខ្ញុំពីពេលមួយទៅពេលមួយ។ យើងខ្ញុំអាចកែប្រែ ឬផ្លាស់ប្តូផ្នែកណាមួយ ឬទាំងអស់នៃសេវាកម្ម មុខងារ និងឧបករណ៍ដែលមានតាមរយៈការប្រើប្រាស់កាតឥណពន្ធ ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួននៃកាតឥណពន្ធ ឬព្យួរ ឬបញ្ឈប់ភាពដែលមាននៃសេវាកម្ម មុខងារ និងឧបករណ៍ណាមួយ ឬទាំងអស់។

### 24.3. ការលុបចោល/ការបញ្ឈប់សេវាកម្មកាតឥណពន្ធ ឬ សេវាកម្មអេឡិចត្រូនិក (Electronic Assess)

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចលុបចោល/បញ្ឈប់សេវាកម្មកាតឥណពន្ធ ឬ សេវាកម្មអេឡិចត្រូនិក (Electronic Assess) ដោយ៖

(ក) មិនចាំបាច់ជូនដំណឹងជាមុន ប្រសិនបើ៖

- ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ជឿជាក់ថាការប្រើប្រាស់កាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬសេវាកម្មអេឡិចត្រូនិកអាចបណ្តាលឱ្យមានការខាតបង់ ដល់ម្ចាស់គណនី ឬធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់
- គណនីដែលមិនដំណើរការ
- រាល់គណនីនានាដែលកាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចប្រើប្រាស់បានត្រូវបិទ
- គណនីដែលដកប្រាក់លើសកំណត់ ឬលើសចំនួនឥណទានដែលលោកអ្នកបានព្រមព្រៀង
- ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានការសង្ស័យថា លោកអ្នកមានការជាប់ពាក់ព័ន្ធនឹងការក្លែងបន្លំ ឬក៏មានការពាក់ព័ន្ធនឹងការប្រព្រឹត្តិមិនត្រឹមត្រូវណាមួយ ឬ

(ខ) ជាមួយការជូនដំណឹង៖

- ម្ចាស់គណនីអាចលុបចោលការប្រើប្រាស់កាតឥណពន្ធ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បានគ្រប់ពេលដោយគ្រាន់តែផ្ញើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬទូរស័ព្ទមកធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ តាមរយៈលេខដែលបានបញ្ជាក់នៅទំព័រខាងក្រោយនៃកូនសៀវភៅនេះ។

ក្រោយពេលបញ្ឈប់គណនីរបស់លោកអ្នក និង/ឬកាតឥណពន្ធរបស់លោកអ្នកក្នុងមូលហេតុណាមួយក៏ដោយ លោកអ្នកនឹងមិនប្រើប្រាស់ ឬប៉ុនប៉ងប្រើប្រាស់ លេខសម្ងាត់ផ្ទាល់ខ្លួន និង/ឬកាតនោះឡើយ។ ក្នុងគោលបំណងរក្សាសុវត្ថិភាព សូមលោកអ្នកកាត់កាតឥណពន្ធជាពីរកំណាត់ និងបោះចោលកាតជាបន្ទាន់។ លោកអ្នកពុំអាចដកយកវិញនូវកម្រៃជំពាក់ដែលកើតឡើងពីការបញ្ឈប់ការប្រើប្រាស់កាតឥណពន្ធក្នុងមូលហេតុណាមួយឡើយ។ ទោះបីជាមានការបញ្ឈប់នេះក៏ដោយ រាល់ការប្រើប្រាស់កាតឥណពន្ធ ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់កាត (ទោះបីជាធ្វើឡើងដោយលោកអ្នក ឬមិនមែន) នឹងត្រូវចាត់ទុកថាការប្រើប្រាស់កាតឥណពន្ធ ឬលេខកូដសម្ងាត់របស់កាតនោះ ធ្វើឡើងដោយលោកអ្នកហើយលោកអ្នកត្រូវទទួលខុសត្រូវនូវរាល់ប្រតិបត្តិការទាំងឡាយដែលកើតមានឡើងដោយប្រើប្រាស់កាតនោះ។ កាតព្វកិច្ចរបស់លោកអ្នកស្របតាមលក្ខខណ្ឌនេះ និងបន្តមានសុពលភាព ហើយយើងខ្ញុំនៅតែមានសិទ្ធិក្នុងការដកប្រាក់ចេញពីគណនីរបស់លោកអ្នក ឬពីគណនីដទៃផ្សេងទៀតដែលលោកអ្នកមានជាមួយធនាគារយើងខ្ញុំលើកម្រៃ និងប្រតិបត្តិការដោយប្រើប្រាស់កាតដែលត្រូវបានធ្វើឡើងមុន ឬក្រោយការបញ្ឈប់គណនីរបស់លោកអ្នក។ លុះត្រាតែ ប្រតិបត្តិការ និងរាល់កម្រៃនានាដែលត្រូវបានកំណត់ក្នុងលក្ខខណ្ឌនេះត្រូវបានទូទាត់សងពេញលេញ លោកអ្នក (និងបុគ្គលណាមួយដែលឈ្មោះ និងគណនីត្រូវបានរក្សាទុក) នៅតែត្រូវទទួលខុសត្រូវចំពោះយើងខ្ញុំ។

### 24.4. ការបញ្ឈប់ដំណើរការរបស់សេវាកម្មអេឡិចត្រូនិក

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចបញ្ឈប់ដំណើរការសេវាកម្មអេឡិចត្រូនិករបស់កាតឥណពន្ធណាមួយតាមរយៈម៉ាស៊ីនអេឡិចត្រូនិកដោយមិនចាំបាច់ជូនដំណឹងជាមុនប្រសិនបើ៖

(ក) ឧបករណ៍អេឡិចត្រូនិកមិនដំណើរការ ឬក៏មិនអាចប្រើប្រាស់បាន

(ខ) ពាណិជ្ជករបដិសេដមិនទទួលយកកាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នក

(គ) មានគណនីណាមួយត្រូវបានដក ឬនឹងត្រូវដកលើសចំនួនសមតុល្យ ឬក៏

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ បានចាត់ទុកថាមិនត្រឹមត្រូវ

(ឃ) ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ជឿជាក់ថាការប្រើប្រាស់គណនីរបស់លោកអ្នកតាមម៉ាស៊ីនអេឡិចត្រូនិកមានការខាតបង់ដល់ម្ចាស់គណនី ឬ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

(ង) ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ជឿជាក់គុណភាព ឬសុវត្ថិភាពនៃដំណើរការអេឡិចត្រូនិក ឬក៏ប្រព័ន្ធដំណើរការធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មិនអាចបំពេញតាមតម្រូវការបាន ឬ

(ច) ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានការសង្ស័យថា លោកអ្នកមានការពាក់ព័ន្ធនឹងការក្លែងបន្លំ ឬ ក៏មានការពាក់ព័ន្ធនឹងការប្រព្រឹត្តិមិនត្រឹមត្រូវណាមួយ ប្រសិនបើមិនមានការហាមឃាត់ដោយច្បាប់។

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ រក្សាសិទ្ធិផ្លាស់ប្តូរប្រភេទគណនីណាមួយដែលអាចត្រូវបានប្រើ ឬប្រភេទប្រតិបត្តិការអេឡិចត្រូនិកណាមួយដែលធ្វើឡើងតាមរយៈម៉ាស៊ីនអេឡិចត្រូនិកនៅពេលណាក៏បាន។

### 24.5. ការផ្លាស់ប្តូរប្រតិបត្តិការតាមរយៈម៉ាស៊ីនអេឡិចត្រូនិក

លោកអ្នកមិនអាចផ្លាស់ប្តូរ កែប្រែ ឬលុបចោលប្រតិបត្តិការណាមួយដែលលោកអ្នកធ្វើឡើងដោយម៉ាស៊ីនអេឡិចត្រូនិកដោយខ្លួនឯងបានឡើយ។

### 24.6. ការចេញរបាយការណ៍ប្រតិបត្តិការ

ពេលលោកអ្នកធ្វើប្រតិបត្តិការតាមរយៈម៉ាស៊ីនអេឡិចត្រូនិក លោកអ្នកនឹងទទួលបានរបាយការណ៍បញ្ជាក់ពីប្រតិបត្តិការរបស់លោកអ្នក។

លោកអ្នកត្រូវពិនិត្យមើលរបាយការណ៍ឱ្យត្រឹមត្រូវ ហើយលោកអ្នកគួររក្សារបាយការណ៍នេះទុកដើម្បីផ្ទៀងផ្ទាត់ និងជួយលោកអ្នកក្នុងការពិនិត្យមើលរបាយការណ៍កែសម្រួលរបស់គណនីរបស់លោកអ្នក។ ក្នុងករណីមានភាពមិនប្រក្រតី ឬបញ្ហាណាមួយរវាងរបាយការណ៍ដែលបានបោះពុម្ពចេញ និង របាយការណ៍អេឡិចត្រូនិកនោះ របាយការណ៍អេឡិចត្រូនិកមានសិទ្ធិជាអទិភាព។

### 24.7. ចំនួនទឹកប្រាក់កំណត់របស់ប្រតិបត្តិការ

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចធ្វើការផ្លាស់ប្តូរ ឬដាក់កំណត់ទៅលើទឹកប្រាក់ដែលអាចប្រើប្រាស់តាមរយៈម៉ាស៊ីនអេឡិចត្រូនិក ក្នុងអំឡុងពេលណាមួយសម្រាប់ប្រតិបត្តិការត្រូវការកាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងលេខសម្ងាត់។ ពាណិជ្ជករ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ក៏អាចដាក់កម្រិតបន្ថែមទៀតទៅលើចំនួនទឹកប្រាក់កំណត់សម្រាប់ប្រតិបត្តិការផងដែរ។

### 24.8. ការទទួលខុសត្រូវរបស់លោកអ្នកចំពោះកាតឥណពន្ធ និងលេខកូដសម្ងាត់របស់លោកអ្នក

សុវត្ថិភាពកាតឥណពន្ធធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកមានសារៈសំខាន់បំផុត។ លោកអ្នកអាចប្រឈមមុខនឹងការប្រើប្រាស់កាតឥណពន្ធ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ និងលេខសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកដោយគ្មានការអនុញ្ញាត ប្រសិនបើលោកអ្នកមិនបានយកចិត្តទុកដាក់ អនុវត្តតាមចំនុចខាងក្រោមនេះទេ។

#### 24.8.1. សុវត្ថិភាពកាតឥណពន្ធ

លោកអ្នកត្រូវតែ៖

- ចុះហត្ថលេខានៅខាងក្រោយកាតឥណពន្ធរបស់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ភ្លាមនៅពេលដែលលោកអ្នកទទួលបានកាត

- កាត់កាតជាពីរតាមខ្សែអង្កត់ទ្រូងភ្លាមនៅពេលកាតអស់សុពលភាព
- មិនត្រូវអនុញ្ញាតឱ្យអ្នកផ្សេងប្រើកាតឥណពន្ធរបស់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នកឡើយ
- ត្រូវរក្សាឥណពន្ធ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ របស់លោកអ្នកឱ្យបានល្អ កុំឱ្យបាត់ ឬចោរលួច លេខកូដសុវត្ថិភាពសម្ងាត់ផ្ទាល់ខ្លួន

### 24.8.2. លេខកូដសម្ងាត់ផ្ទាល់ខ្លួន

លោកអ្នកត្រូវតែះ

- មិនត្រូវប្រាប់លេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកទៅអ្នកផ្សេងទៀតឡើយ
- កុំឱ្យអ្នកណាម្នាក់ដឹង ឬឃើញលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក
- ព្យាយាមចងចាំលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកជាជាងកត់ទុកនៅកន្លែងណាមួយ
- មិនត្រូវជ្រើសរើសលេខសម្ងាត់ផ្ទាល់ខ្លួនណាដែលស្រួលចាំឡើយ ឧទាហរណ៍ លេខ ឬអក្សរដូចៗគ្នា និង
- មិនត្រូវជ្រើសរើសលេខសម្ងាត់ផ្ទាល់ខ្លួនដែលងាយស្រួលស្មាន ឧទាហរណ៍ថ្ងៃខែឆ្នាំកំណើត លេខរថយន្ត លេខទូរស័ព្ទ ឬឈ្មោះរបស់លោកអ្នកឡើយ។

ការប្រើប្រាស់កាតឥណពន្ធ ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួនណាមួយ ត្រូវអនុលោម តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ និងស្របតាមលក្ខខណ្ឌតម្រូវ ការកម្រិត និង នីតិវិធីដែលត្រូវបានកំណត់ដោយ Visa ពីពេលមួយទៅពេលមួយ និងលក្ខខណ្ឌ ដែលកំណត់ដោយធនាគារយើងខ្ញុំពីពេលមួយទៅពេលមួយ ពាក់ព័ន្ធនឹងសេវាកម្ម អេឡិកត្រូនិក ឧបករណ៍និងប្រតិបត្តិការដោយប្រើប្រាស់កាត។ ប្រតិបត្តិការដក សាច់ប្រាក់ត្រូវអនុលោមតាមលក្ខខណ្ឌ ដែលត្រូវបានកំណត់ដោយយើងខ្ញុំពី ពេលមួយទៅពេលមួយ។

លោកអ្នកមិនត្រូវប្រើប្រាស់កាតឥណពន្ធ ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួន (ទោះបីជាដើម្បីធ្វើប្រតិបត្តិការទូទាត់ ឬផ្សេងពីនេះ) ពាក់ព័ន្ធនឹងប្រតិបត្តិការ ឬ សកម្មភាព ណាមួយខុសច្បាប់ ឬ ហាមឃាត់ក្រោមច្បាប់នៃប្រទេសដែលធ្វើប្រតិបត្តិការនោះ ឬសកម្មភាពនោះកើតឡើង ឬច្បាប់នៃប្រទេសដែលលោកអ្នករស់នៅ។

ប្រសិនបើលេខកូដសម្ងាត់ផ្ទាល់ខ្លួនត្រូវបានផ្តល់ជូនលោកអ្នកជាមួយនឹងកាតតាមម៉ាស៊ីន ATM ណាមួយះ

- នោះលោកអ្នកអាចប្រើប្រាស់កាតនោះជាមួយម៉ាស៊ីន ATM ណាក៏បាន។ កាតនោះអាចប្រើប្រាស់បានដោយលោកអ្នកតែម្នាក់គត់ និងមិនអាចផ្ទេរបានឡើយ និង
- នៅពេលដែលលោកអ្នកប្រើប្រាស់កាតឥណពន្ធ ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួន តាមម៉ាស៊ីន ATM ណាមួយដើម្បីធ្វើប្រតិបត្តិការដោយប្រើប្រាស់កាតដែលអាចនឹងត្រូវធ្វើបានតាមរយៈការប្រើប្រាស់កាត ATM កាតឥណពន្ធនោះ និងត្រូវចាត់ទុកជាកាត ATM សម្រាប់គោលបំណងប្រើប្រាស់នាខណៈពេលប្រើហើយលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការប្រើប្រាស់កាត ATM នឹងត្រូវយកមកអនុវត្តក្នុងការគ្រប់គ្រងលើរាល់ប្រតិបត្តិការដោយប្រើប្រាស់កាតដែលត្រូវបានបង្កើតឡើងដែលសមរម្យ និងមានភាពពាក់ព័ន្ធគ្នា។

### 24.8.3. ការបាត់ ឬត្រូវបានចោរលួចកាតឥណពន្ធ ឬកំណត់ត្រាលេខកូដសម្ងាត់ផ្ទាល់ខ្លួន

ប្រសិនបើលោកអ្នកដឹងថា កាតឥណពន្ធរបស់លោកអ្នកត្រូវបានបាត់ ឬចោរលួច ឬត្រូវបានប្រើប្រាស់ដោយពុំមានការអនុញ្ញាត លោកអ្នកត្រូវជូនដំណឹងមកកាន់ យើងខ្ញុំអំពីការបាត់ ឬការលួច ឬការប្រើប្រាស់ដោយពុំមានការអនុញ្ញាតដោយ ទូរស័ព្ទមកកាន់សេវាកម្មបម្រើអតិថិជន (Customer Care Center) ឬតាមរយៈការជូនដំណឹងមកកាន់យើងខ្ញុំជាលាយលក្ខណ៍អក្សរ។ ក្នុងកាលៈទេសៈជាក់ស្តែងណាមួយ យើងខ្ញុំអាចស្នើសុំឱ្យលោកអ្នកធ្វើរបាយការណ៍ប៉ូលីស ភ្ជាប់ជាមួយនឹងការអះអាងជាលាយលក្ខណ៍អក្សរនូវការបាត់បង់ ឬការលួច ឬ ការប្រើប្រាស់ដោយពុំមានការអនុញ្ញាត ឬការបង្ហាញអោយដឹង និងព័ត៌មានផ្សេងៗ ដែលយើងខ្ញុំតម្រូវ។

ប្រសិនបើកាតឥណពន្ធរបស់លោកអ្នកត្រូវបានបាត់ ឬ ត្រូវបានលួច ឬប្រសិនបើលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកត្រូវបានគេដឹង លោកអ្នកនឹងមិនត្រូវ បានទទួលខុសត្រូវលើប្រតិបត្តិការដោយប្រើប្រាស់កាតដែលធ្វើឡើងដោយសារការបាត់ ឬ ការលួច ឬការបង្ហាញអោយដឹង លុះត្រាតែយើងខ្ញុំទទួលបានការជូនដំណឹងពីការបាត់ ឬការលួច ឬការបង្ហាញអោយដឹងនោះដូចខាងក្រោម៖

(1) លោកអ្នកបានជូនដំណឹងមកកាន់យើងខ្ញុំភ្លាមៗ

(2) លោកអ្នកបានផ្តល់ជំនួយក្នុងការប្រមូលមកវិញនូវប្រាក់ និង/ឬ ទំនិញដែលតតិយជនណាមួយបានទទួលបាន ដោយមិនត្រឹមត្រូវ និង/ឬការទិញដែលបណ្តាលមកពីការបាត់ ឬការលួច ឬការបង្ហាញ អោយដឹង ហើយទូទាត់សងមកកាន់យើងខ្ញុំភ្លាមៗ

(3) លោកអ្នកបានផ្តល់ជូនយើងខ្ញុំ នូវសេចក្តីប្រកាសអះអាងក្នុងទម្រង់ដូចដែលយើងខ្ញុំបានកំណត់ ឬរបាយការណ៍ប៉ូលីស និងរាល់គ្រប់ ឯកសារផ្សេងទៀត ឬជំនួយនានាដែលយើងខ្ញុំតម្រូវ

(4) យើងខ្ញុំយល់ស្របថា ការបាត់ ការលួច ឬការបង្ហាញអោយដឹងនោះមិនត្រូវបានកើតឡើងពីការធ្វេសប្រហែស ការបន្លំ ឬ កំហុសរបស់លោកអ្នក និង

(5) កាតឥណពន្ធរបស់លោកអ្នក មិនត្រូវបានប្រើប្រាស់ជាកាត ATM នៅក្នុងប្រតិបត្តិការដោយប្រើប្រាស់កាតដែលមានបញ្ហា។

លោកអ្នកនឹងមិនទទួលខុសត្រូវលើប្រតិបត្តិការដោយប្រើប្រាស់កាតណាមួយ ដែលធ្វើឡើងបន្ទាប់ពីយើងខ្ញុំទទួលបានការជូនដំណឹង អំពីការបាត់ ឬការលួច ឬការបង្ហាញអោយដឹង។ យ៉ាងណាមិញ យើងខ្ញុំនឹងដកប្រាក់ចេញពីគណនីដែលពាក់ព័ន្ធលើប្រតិបត្តិការដោយប្រើប្រាស់កាតដែលមានបញ្ហាទាំងអស់ ដែលត្រូវបានធ្វើឡើងមុនពេលយើងទទួលបានការជូនដំណឹងអំពីការបាត់ ឬការលួច ឬការបង្ហាញអោយ ដឹង លុះត្រាតែចំណុច (1) ដល់ (5) ខាងលើត្រូវបានបំពេញ។

ខណៈដែលកាតឥណពន្ធត្រូវបានរាយការណ៍ថាបានបាត់ ឬលួច កាតនោះនឹងមិនអាចត្រូវបានប្រើប្រាស់ទៀតទេ ប្រសិនបើកាតនោះត្រូវបានរកឃើញវិញ។ លោកអ្នកត្រូវកាត់កាតដែលត្រូវបានរកឃើញវិញនោះជាបំណែកៗ។ រាល់កាតឥណពន្ធដែលត្រូវបោះចោល ត្រូវតែកាត់ជាបំណែកៗ។ លោកអ្នកត្រូវទទួលខុសត្រូវលើរាល់ការបាត់បង់ ឬខូចខាតនានា ដែលកើតឡើងពីកំហុសនៃការមិនធ្វើតាមសេចក្តីណែនាំដូចខាងលើ។

យើងខ្ញុំនឹងផ្តល់កាតថ្មីជំនួស ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួនថ្មីតាមឆន្ទានុសិទ្ធិរបស់យើងខ្ញុំស្របតាមលក្ខខណ្ឌដែលយើងខ្ញុំយល់ឃើញថាសមស្រប ហើយយើងខ្ញុំ សូមរក្សាសិទ្ធិធ្វើការគិតថ្លៃដូរកាតថ្មីដែលបានកំណត់ក្នុងសេចក្តីណែនាំស្តីពីតម្លៃពាក់ព័ន្ធនឹងរាល់ការបាត់បង់ ឬការលួចកាត។ ថ្លៃសេវាកម្មនេះ នឹងត្រូវបានដកចេញពីគណនី

ហើយមិនអាចដកយកវិញបានឡើយ។

**24.9. កាតឥណពន្ធរង**

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចចេញកាតឥណពន្ធរងទៅកាន់ម្ចាស់គណនីរួមដទៃណាមួយ ប្រសិនបើម្ចាស់គណនីរួមនោះបំពេញបានគ្រប់លក្ខខណ្ឌតម្រូវ ដែលត្រូវសម្រេចដោយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ តែមួយគត់ពីពេលមួយទៅពេលមួយ។

កាតព្វកិច្ចណាមួយ និងទាំងអស់របស់ម្ចាស់គណនីរួមនឹងត្រូវបានកើតមានឡើងលើគណនីរួម និងកាតឥណពន្ធ គឺជាកាតព្វកិច្ចរួមគ្នា។

សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់គណនីរួមដែលពាក់ព័ន្ធនឹងគណនី និងកាតឥណពន្ធត្រូវអនុលោមតាមបញ្ញត្តិស្តីពីគណនីរួមដូចមានចែងក្នុងប្រការ 7។

**24.10. ប្រតិបត្តិការបង្វិលប្រាក់សងវិញ**

លោកអ្នកអាចត្រូវបានផ្តល់សិទ្ធិក្នុងការធ្វើប្រតិបត្តិការទទួលយកប្រាក់បង្វិលសងវិញនៅកន្លែងដែលលោកអ្នកមានបញ្ហាជាមួយពាណិជ្ជករ។ ឧទាហរណ៍ លោកអ្នកអាចត្រូវបានផ្តល់សិទ្ធិដើម្បីធ្វើប្រតិបត្តិការទទួលយកប្រាក់បង្វិលសងវិញនៅពេលដែលពាណិជ្ជករមិនបានផ្តល់ជូនលោកអ្នកនូវទំនិញ ឬ សេវាកម្មមានគុណភាពល្អដែលលោកអ្នកបានចំណាយលើ។ លោកអ្នកត្រូវជូនដំណឹងទៅកាន់អ្នកផ្តល់កាត ប្រសិនបើលោកអ្នកជឿជាក់ថា លោកអ្នកមានសិទ្ធិក្នុងការធ្វើប្រតិបត្តិការទទួលយកប្រាក់បង្វិលសងវិញ។ ប្រសិនបើអ្នកផ្តល់កាតយល់ស្របថា លោកអ្នកមានសិទ្ធិក្នុងការធ្វើប្រតិបត្តិការទទួលប្រាក់បង្វិលសងវិញ នោះយើងខ្ញុំនឹងដាក់ចូលក្នុងគណនីរបស់លោកអ្នកនូវចំនួនទឹកប្រាក់ដែលត្រូវបានដកចេញលើកដំបូងសម្រាប់ប្រតិបត្តិការនោះ។

លោកអ្នកគួរតែជូនដំណឹងជាបន្ទាន់ទៅកាន់អ្នកផ្តល់កាតអំពីប្រតិបត្តិការដែលមានបញ្ហា។ មុខងារប្រព័ន្ធប្រតិបត្តិការរបស់កាតឥណពន្ធបានកំណត់រយៈពេលផុតកំណត់សុពលភាពរបស់ប្រតិបត្តិការដែលអ្នកផ្តល់កាតមិនអាចបំពេញប្រតិបត្តិការ បង្វិលប្រាក់សងជូនវិញបាន។ រយៈពេលកំណត់អប្បបរមា ជាទូទៅគឺ 75 ថ្ងៃបន្ទាប់ពីប្រតិបត្តិការដែលមានបញ្ហា ប៉ុន្តែរយៈពេលកំណត់ខ្លះអាចយូរជាងនេះ។ ប្រសិនបើលោកអ្នកមិនបានជូនដំណឹងមកកាន់អ្នកផ្តល់កាតទាន់ពេលវេលាទេ អ្នកផ្តល់កាតមិនអាច ពិនិត្យផ្ទៀងផ្ទាត់មើលការតវ៉ារបស់លោកអ្នកទេ ហើយលោកអ្នកត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការនោះ។

លោកអ្នកត្រូវទទួលខុសត្រូវពិនិត្យផ្ទៀងផ្ទាត់មើលដោយយកចិត្តទុកដាក់លើរបាយការណ៍គណនីរបស់លោកអ្នក។ អ្នកផ្តល់កាតមិនទទួលខុសត្រូវចំពោះការបាត់បង់នានាទេប្រសិនបើលោកអ្នកមិនបានស្នើសុំធ្វើប្រតិបត្តិការបង្វិលប្រាក់សងវិញនៅក្នុងរយៈពេលកំណត់។

**24.11. ការដកចេញ និងការលើកលែង**

24.11.1. ធនាគារយើងខ្ញុំ មិនទទួលខុសត្រូវនៅក្នុងរូបភាពណាក៏ដោយ ប្រសិនបើលោកអ្នកជួបប្រទះនឹងបញ្ហាជាមួយនឹងទំនិញ និងសេវាកម្មដែលលោកអ្នកបានទិញតាមរយៈការប្រើប្រាស់កាតរបស់លោកអ្នក ឬ សេវាកម្មអេឡិចត្រូនិក ហើយធនាគារយើងខ្ញុំក៏មិនទទួលខុសត្រូវលើផលប្រយោជន៍ ការបញ្ចុះតម្លៃ ឬកម្មវិធីរបស់ពាណិជ្ជករណាមួយដែលយើងខ្ញុំធ្វើអោយមានសម្រាប់លោកអ្នក។ ទោះបីជាមានការមិនប្រគល់ជូន ឬ ការមិនបំពេញកាតព្វកិច្ច ឬការខូចខាតចំពោះទំនិញ និងសេវាកម្ម យើងខ្ញុំមានសិទ្ធិដកប្រាក់ចេញពីគណនីរបស់លោកអ្នក ឬ គណនីណាមួយដែលលោកអ្នករក្សាជាមួយយើងខ្ញុំក្នុងចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការដោយប្រើប្រាស់កាត។ លោកអ្នកនឹងដោះស្រាយបញ្ហានានាដោយផ្ទាល់ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ឬ ពាណិជ្ជករ។ រាល់បញ្ហា គឺជាបញ្ហារវាងលោកអ្នក និងអ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ឬពាណិជ្ជករ ហើយធនាគារយើងខ្ញុំមិនត្រូវចាត់ទុកជាភាគីនៃបញ្ហានោះឡើយ។ យើង

ខ្ញុំមិនទទួលខុសត្រូវលើបរិមាណគុណភាព ភាពដែលអាចធ្វើពាណិជ្ជកម្មបាន ភាពសមស្របតាមគោលបំណង ឬ បញ្ហាណាមួយដែលកើតឡើងលើទំនិញ និងសេវាកម្មដែលផ្គត់ផ្គង់ទៅកាន់ លោកអ្នក ឬពាក់ព័ន្ធនឹងកិច្ចសន្យាណាមួយ ឬប្រតិបត្តិការដែលបង្កើតឡើងដោយអ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ឬពាណិជ្ជករដែលលោកអ្នកបានជាប់ពាក់ព័ន្ធតាមរយៈការប្រើប្រាស់កាត។ ការទទួលខុសត្រូវរបស់លោកអ្នកចំពោះយើងខ្ញុំមិនត្រូវបានប៉ះពាល់ទោះក្នុងរូបភាពណាក៏ដោយ ដោយសារបញ្ហានោះ ឬការប្ដឹងតវ៉ាទាមទារសិទ្ធិទាមទារ ឬសិទ្ធិក្នុងកិច្ចសន្យាដែលលោកអ្នកមានតទល់នឹងពាណិ-ជ្ជករ ឬបុគ្គលណាមួយ។

24.11.2.

(ក) លោកអ្នកទទួលយល់ព្រមថា ទំនាក់ទំនង និងការរៀបចំសម្រាប់សេវាកម្មជំនួយសង្គ្រោះបន្ទាន់អន្តរជាតិ (International Emergency Assistance Service) (ដែលអាចមានសម្រាប់កាតឥណពន្ធ) គឺត្រូវបាន ផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់សេវាកម្មភាគីទី3។

(ខ) លោកអ្នកទទួលខុសត្រូវលើការចំណាយលើផ្នែកវេជ្ជសាស្ត្រផ្នែកច្បាប់ ឬសេវាកម្មដទៃដែលត្រូវបានប្រើប្រាស់ហើយលោកអ្នកទទួលស្គាល់ថា៖ ជំនួយនឹងត្រូវផ្ដល់ជូនក្នុងមូលដ្ឋាននៃការប្រឹងប្រែងអស់ពីសមត្ថភាព ហើយអាចមិនទទួលបាន អាស្រ័យដោយពេលវេលា ចម្ងាយ ឬទីតាំង។

(គ) លោកអ្នកមិនត្រូវអោយយើងខ្ញុំ ឬវីសាទទួលខុសត្រូវលើការប្រើប្រាស់ ការប្រព្រឹត្តិ ការខកខាន ការបាត់បង់ ឬការខូចខាតដែលកើតមានឡើងបណ្ដាលមកពីសេវាកម្មវេជ្ជសាស្ត្រ សេវាកម្មច្បាប់ ឬសេវាកម្មដឹកជញ្ជូននោះ។

24.11.3. យើងខ្ញុំមិនទទួលខុសត្រូវក្នុងគ្រប់រូបភាពទាំងអស់ ដោយផ្ទាល់ ដោយមិនផ្ទាល់ ដោយពិសេស ឬដោយសំខាន់ ដោយសេដ្ឋកិច្ច ឬការខូចខាតណាមួយដែលកើតឡើង ពីបទបញ្ញត្តិ និង/ឬការប្រើប្រាស់សេវាកម្ម អេឡិចត្រូនិក ឬការប្រើប្រាស់កាតរបស់លោកអ្នក។

24.11.4. យើងខ្ញុំអាចសម្រេច ឬអនុញ្ញាតសិទ្ធិដោយឆន្ទានុសិទ្ធិរបស់យើងខ្ញុំ និងដោយពុំចាំបាច់មានការជូនដំណឹងមុន ចំពោះប្រតិបត្តិការមិនបង្ហាញកាតដែលលោកអ្នកត្រូវទទួលខុសត្រូវលើរាល់ប្រតិបត្តិការមិនបង្ហាញកាតធ្វើឡើងតាមរយៈការប្រើប្រាស់កាតរបស់លោកអ្នកក្នុងមូលហេតុណាមួយក៏ដោយ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះលោកអ្នកនៅគ្រប់រូបភាពណាក៏ដោយលើការអនុញ្ញាតសិទ្ធិដែលត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងប្រតិបត្តិការមិនបង្ហាញកាត។

24.11.5. លោកអ្នកយល់ព្រមថាការប្រើប្រាស់កាត និងសេវាកម្មអេឡិចត្រូនិកគឺជាហានិភ័យរបស់លោកអ្នក ហើយលោកអ្នកត្រូវសន្មតទុកជាមុននូវរាល់ហានិភ័យដែលអាចកើតមានឡើងចំពោះការប្រើប្រាស់កាតនោះ។

24.11.6. យើងមិនទទួលខុសត្រូវចំពោះលោកអ្នកលើគ្រប់រូបភាពទាំងអស់ដូចខាងក្រោម៖

(1) លើការយឺតយ៉ាវ ឬប្រសិនបើយើងខ្ញុំពុំអាចអនុវត្តការទទួលខុសត្រូវរបស់យើងខ្ញុំដូចមានចែងក្រោមលក្ខខណ្ឌនៃកិច្ចសន្យានេះដែលធនាគារយើងខ្ញុំ ឬបុគ្គលិកយើងខ្ញុំ ភ្នាក់ងារ ឬម្ចាស់កិច្ចសន្យាមិនអាចគ្រប់គ្រងបានដោយបណ្ដាលមកពីមូលហេតុ ផ្សេងៗ។ ចំណុចនេះរួមបញ្ចូលតែមិនកំណត់ត្រឹមរាល់ប្រព័ន្ធអេឡិចត្រូនិក ប្រព័ន្ធមេកានិក ការដំណើការទិន្នន័យ ឬការបាត់បង់ទំនាក់ទំនង ឬការបរាជ័យ ជម្លោះឧស្សាហកម្ម ភាពចលាចលសង្គម សង្គ្រាមឬប្រធានសក្តិ។

(2) ប្រសិនបើក្រុមហ៊ុនណាមួយបានបដិសេធមិនព្រមទទួលកាតដោយសារមូលហេតុណាមួយ។

(3) លើការប៉ះពាល់ចំពោះកិត្តិយស អត្តចរិត និងកេរ្តិ៍ឈ្មោះរបស់លោកអ្នក ប្រសិនបើប្រតិបត្តិការដោយប្រើប្រាស់កាតមិនអាចដំណើរការបាន ឬប្រសិនបើយើងខ្ញុំស្នើសុំអោយប្រគល់កាតមកវិញ។

(4) ប្រសិនបើមានការមិនទទួលនូវកាត ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកដោយពាណិជ្ជករ ឬម៉ាស៊ីនណាមួយដែលត្រូវបានប្រើប្រាស់ដើម្បីដំណើរការប្រតិបត្តិការដោយប្រើប្រាស់កាត ឬប្រសិនបើយើងខ្ញុំបដិសេធដោយមូលហេតុណាមួយនូវការអនុញ្ញាតសិទ្ធិលើប្រតិបត្តិការដោយប្រើប្រាស់កាតណាមួយ។

(5) លើការមិនដំណើការ ការខូចខាត ឬកំហុសបច្ចេកទេស ឬម៉ាស៊ីនណាមួយដែលត្រូវបានប្រើប្រាស់ដើម្បីដំណើរការប្រតិបត្តិការ ដោយប្រើប្រាស់កាត ឬម៉ាស៊ីនណាមួយ ឬប្រព័ន្ធនៃការអនុញ្ញាតសិទ្ធិ ទោះបីជាកម្មសិទ្ធិ ឬដាក់ឱ្យដំណើរការដោយយើងខ្ញុំ ឬបុគ្គលណាមួយ ឬភាពមិនអាចដំណើរការបាននៃម៉ាស៊ីនឬប្រព័ន្ធអោយបានច្បាស់លាស់ត្រឹមត្រូវ ឬផ្អែរភ្លាមៗដំណើរការ ឬរក្សាទិន្នន័យ។

(6) លើការខូចខាត ឬការបាត់បង់ ឬភាពមិនអាចដំណើរការបានក្នុងការទាញយកមកវិញនូវទិន្នន័យ ឬព័ត៌មានដែលត្រូវបានរក្សាទុកក្នុងកាតរបស់លោកអ្នក ឬមីក្រូឈីប (Microchip) ឬសៀគ្វី (Circuit) ឬឧបករណ៍ក្នុងកាតរបស់លោកអ្នក ឬខូចខាតទិន្នន័យ ឬព័ត៌មានទាំងនោះ។

(7) លើការប្រតិបត្តិតាមរបស់យើងខ្ញុំចំពោះរាល់ការបញ្ជា ឬការអះអាងថា ត្រូវទទួលបានការបញ្ជាពីលោកអ្នកទាក់ទងនឹងសេវាកម្មអេឡិចត្រូនិក ទោះបីជាមានភាពទាំងមូលនៃព័ត៌មានដែលភ្ជាប់ជាមួយនឹងការបញ្ជានោះ អាចត្រូវបានធ្វើអោយអន់ថយ ឬខូចខាតខណ:ពេលបញ្ជូននោះ ការធ្វើអោយអន់ថយ ឬខូចខាតនោះមិនអាចមានភាពច្បាស់លាស់ចំពោះបុគ្គលទូទៅដែលទទួលបានបញ្ជានោះឡើយ។

(8) លើការរាំងស្ទះដោយ ឬការបង្ហាញអោយដឹងដល់បុគ្គលណាមួយ(ទោះបីជាដោយស្របច្បាប់ ឬ ផ្សេងពីនេះ) នូវរាល់ទិន្នន័យ ឬ ព័ត៌មានពាក់ព័ន្ធនឹងលោកអ្នក ឬប្រតិបត្តិការដោយប្រើប្រាស់កាតណាមួយ ឬគណនីដែលបញ្ជូនតាម ឬ រក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ ឧបករណ៍ផ្ទុកទិន្នន័យ (Medium)។

(9) ប្រសិនបើលោកអ្នកត្រូវបានដកហូតការប្រើប្រាស់ សេវាកម្មអេឡិចត្រូនិកដែលបណ្តាលមកពីសកម្មភាពនានារបស់យើងខ្ញុំ។

(10) សេវាកម្មអេឡិចត្រូនិកនានា ដែលមិនអាចផ្តល់ជូនដោយហេតុមកពីការជួសជុលប្រព័ន្ធ ឬការខូច ឬភាពមិនអាចដំណើរការបាននៃប្រព័ន្ធណេតវីក៖

(11) (ក) លើការបាត់បង់ ការលួច ការប្រើប្រាស់ត្រឹមត្រូវ ឬការប្រើប្រាស់ខុសនៃកាត ឬ ការបង្ហាញអោយដឹងនូវលេខសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក និង/ឬការបំពានលក្ខខណ្ឌ

(ខ) លើការបន្លំបោកប្រាស់ និង/ឬ ការក្លែងឯកសារដែលធ្វើឡើងលើធនាគារយើងខ្ញុំ ឬពាណិជ្ជករណាមួយ និង/ឬ

(12) លើការយឺតយ៉ាវ ភាពមិនដំណើរការ ឬកំហុសដោយយើងខ្ញុំដើម្បីអនុវត្តកាតព្វកិច្ចណាមួយរបស់យើងខ្ញុំ អនុលោមតាមកិច្ចព្រមព្រៀងនេះ ដែលបណ្តាលមកពី ឬ រួមចំណែកក្នុងរូបភាពណាមួយដោយហេតុការណ៍មួយ

ឬច្រើន ឬការកើតឡើងនូវព្រឹត្តិការណ៍ណាមួយដែលកំណត់ក្នុងប្រការនេះ។

## 25. ភាពមិនត្រូវគ្នា

ក្នុងករណីដែលមានភាពមិនត្រូវគ្នារវាងភាសាអង់គ្លេស និងភាសាខ្មែរនៅក្នុងឯកសារនេះ ភាសាអង់គ្លេស នឹងមានសិទ្ធិចំពោះវិសាលភាពនៃភាពមិនចុះសម្រុងគ្នានេះ។

## 26. ការផ្ទេរសិទ្ធិ

លោកអ្នកមិនអាចផ្ទេរសិទ្ធិ និង/ឬកំណត់ផ្នែកណាមួយ ឬផ្នែកទាំងអស់នៃសិទ្ធិរបស់លោកអ្នក អត្ថប្រយោជន៍ និង ឬកាតព្វកិច្ចរបស់លោកអ្នកចំពោះលក្ខខណ្ឌទាំងនេះ ឬឯកសារណាមួយដែលពាក់ព័ន្ធដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ។

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចផ្ទេរ និង/ឬកំណត់ផ្នែកណាមួយ ឬផ្នែកទាំងអស់នៃសិទ្ធិរបស់ខ្លួន អត្ថប្រយោជន៍ និងឬកាតព្វកិច្ចរបស់ខ្លួនចំពោះលក្ខខណ្ឌទាំងនេះ ឬឯកសារណាមួយដែលពាក់ព័ន្ធទៅឱ្យក្រុមហ៊ុន សាខាក្នុងស្រុករបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ក្រោមការវិនិច្ឆ័យដែលធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ឬសាខាសម្ព័ន្ធរបស់ខ្លួនដោយមិនចាំបាច់មានការយល់ព្រមពីលោកអ្នក។ ដើម្បីបង្កភាពងាយស្រួលដល់ដំណើរការផ្ទេរ និងឬកំណត់ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ត្រូវផ្តល់សិទ្ធិក្នុងការបង្ហាញព័ត៌មានដែលពាក់ព័ន្ធដល់សាខា ឬសាខាសម្ព័ន្ធរបស់ខ្លួន ហើយលោកអ្នកយល់ព្រមទទួលស្គាល់អនុវត្ត និងចុះហត្ថលេខាលើឯកសារផ្សេងៗនៅពេលដែលមានការស្នើសុំដោយសមហេតុផលពីធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដើម្បីបំពេញឯកសារយល់ព្រម ឬការចុះឈ្មោះដែលមានការចាំបាច់សម្រាប់ការផ្ទេរ និងឬកំណត់។

## 27. ច្បាប់គ្រប់គ្រង

លក្ខខណ្ឌទាំងនេះមានតម្លៃ និងភាពស្របច្បាប់ក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ លោកអ្នក និងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចយល់ព្រមដោះស្រាយរាល់វិវាទដែលកើតឡើងក្រោមលក្ខខណ្ឌតាមរយៈយុត្តាធិការតុលាការដែលមានសមត្ថកិច្ច។

## 28. ពន្ធ

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ អាចមានការចាំបាច់ក្នុងការកាត់ទុកនូវទឹកប្រាក់ដែលបានបង់ចំពោះម្ចាស់គណនីមួយចំនួន រួចផ្ទេរទឹកប្រាក់នោះទៅឱ្យរដ្ឋាភិបាលក្នុងស្រុក ឬបរទេស ឬ អជ្ញាធរប្រមូលចំណូលយោងតាមច្បាប់ក្នុងស្រុក ឬបរទេស ក្នុងកិច្ចព្រមព្រៀងជាមួយនឹងអជ្ញាធរទាំងនេះ។

ប្រសិនបើនៅពេលណាមួយ ទីភ្នាក់ងាររដ្ឋាភិបាលក្នុងស្រុក ឬ បរទេស ឬ អជ្ញាធរប្រមូលចំណូលតម្រូវឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ធ្វើការកាត់ទុក ឬដកចំនួនទឹកប្រាក់ណាមួយដែលត្រូវបង់ជូនលោកអ្នក លោកអ្នកយល់ព្រមភ្លាមក្នុងការសងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ សម្រាប់ចំនួនទឹកប្រាក់នៃការកាត់ទុក ឬ ដកទុកនោះរួមទាំងអនុញ្ញាតឱ្យ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ កាត់ទឹកប្រាក់ទាំងនេះពីគណនីលោកអ្នកផងដែរ។ លោកអ្នកត្រូវចេញសងធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ចំពោះការខាតបង់ ឬការចំណាយរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ដែលបានកើតឡើងដោយសារការកាត់ទុក ឬការដកទុកនោះ។

## 29. ការប្រមូលព័ត៌មាន

លោកអ្នកយល់ព្រមផ្តល់ឱ្យ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នូវព័ត៌មាន និងឯកសារទាំងអស់តាមការតម្រូវម្តងម្កាលរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ រួមទាំងតម្រូវការផ្សេងៗផងដែរយោងតាមច្បាប់ ឬច្បាប់បទបញ្ញត្តិបរទេស និងឬតាមរយៈកិច្ចព្រមព្រៀងជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាល ឬអជ្ញាធរប្រមូលចំណូល (ទោះជាក្នុងស្រុកក្តី ឬ

បរទេសក្តី) ដើម្បីធ្វើការសាកសួរអំពីស្ថានភាពពន្ធរបស់លោកអ្នក។ លោកអ្នកទទួលស្គាល់ថា ព័ត៌មានទាំងអស់ដែលផ្តល់ឱ្យធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានភាពត្រឹមត្រូវពេញលេញ មានបច្ចុប្បន្នភាព និងមិនបង្កឱ្យមានការយល់ច្រលំឡើយ។

## 30. ទំនាក់ទំនងតាមទូរស័ព្ទ

ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានឆន្ទានុសិទ្ធក្នុងការត្រួតពិនិត្យ និងថតសំលេងរាល់ទំនាក់ទំនងតាមទូរស័ព្ទរបស់លោកអ្នក។ គោលបំណងនៃការថតសំលេងនេះ គឺសំរាប់ត្រួតពិនិត្យគុណភាព ការផ្ទៀងផ្ទាត់ជាភស្តុតាងនៅក្នុងនីតិវិធីតុលាការ ឬរដ្ឋបាល និងការបណ្តុះបណ្តាល។

## សាខាធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់

### រាជធានីភ្នំពេញ

**សាខាក្រមួនស (ការិយាល័យកណ្តាល)**
ផ្ទះលេខ 20 វិថីក្រមួនស
កែងផ្លូវលេខ 67

**សាខាវិមានឯករាជ្យ**
ផ្ទះលេខ 100
មហាវិថីសម្តេចព្រះសីហនុ

**សាខាផ្សារអូឡាំពិក**
ផ្ទះលេខ 259-361-363
មហាវិថីសម្តេចព្រះសីហនុ

**សាខាមាត់ទន្លេ**
ផ្ទះលេខ 265 តីរវិថីព្រះស៊ីសុវត្ថិ

**សាខាផ្សារដើមថ្កូវ**
ផ្ទះលេខ 616A-B ផ្លូវលេខ 271

**សាខាពេទ្យលោកសង្ឃ**
ផ្ទះលេខ 1A-1B ផ្លូវលេខ 271

**សាខាទឹកថ្លា**
ផ្ទះលេខ 1E0-1E1 ផ្លូវលេខ 110A

**សាខាស្ទឹងមានជ័យ**
ផ្ទះលេខ 23-25A ផ្លូវ 217

**សាខាចោមចៅ**
ផ្ទះលេខ 1B-2B និង 3B
ផ្លូវជាតិលេខ4

**សាខាទួលគោក**
ផ្ទះលេខ95 C មហាវិថីលេខ289

**សាខាសែនសុខ**
អគារលេខ ៤ ផ្លូវ ១០០៣
សង្កាត់ភ្នំពេញថ្មី

**សាខាច្បារអំពៅ**
ផ្ទះលេខ ៧២ អេ បី ស៊ី ឌី
ផ្លូវជាតិលេខ ១ សង្កាត់និរោធ

**សាខាជ្រោយចង្វារ**
ផ្ទះលេខ អេហ្វ០៥ ផ្លូវជាតិលេខ ៦អា
សង្កាត់ព្រែកលៀប

### សាខាខេត្ត

**សាខាខេត្តសៀមរាប ផ្សារកណ្តាល**
ផ្ទះលេខ 566-568 និង 570
ផ្លូវទេពវង្ស

**សាខាខេត្តព្រះសីហនុ**
ផ្ទះលេខ 215 វិថីឯករាជ្យ

**សាខាខេត្តបាត់ដំបង**
ផ្ទះលេខ 2-4 និង 6 ផ្លូវលេខ 1

**សាខាខេត្តកំពង់ចាម**
វិថីព្រះមុន្នីវង្ស
កែងវិថីនារីរ័ត្នកុសុមៈ

J Trust Royal Bank

ទូរសព្ទ៖ +855 23 999 000
អ៊ីម៉ែល៖ ccc@jtrustroyal.com
SWIFT៖ TCABKHPP
គេហទំព័រ៖ www.jtrustroyal.com